**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université royale de droit et des sciences Economiques**

**Royal University of Law and Econimics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីព្រហ្មទណ្ឌក្នុងដំណាក់កាលអយ្យការ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឆាយ លីនណា**

**សុខ សិរី**

សាស្ត្រាចារ្យណែនាំ

លោក **ហោ សុភ័ណ្ឌា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៨

ជំនាន់ទី ២១

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ឆាយ លីនណា** និង នាងខ្ញុំឈ្មោះ **សុខ សិរី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តឆ្នាំទី៤ ជំនាន់ទី២១ ឆ្នាំសិក្សា២០២០-២០២១ នៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមថ្លែងនូវសេចក្តីកត្តញ្ញូតាធម៌ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- លោកឪពុក អ្នកម្តាយដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថ្នាក់ថ្នមថែរក្សា ទូន្មាន ប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ ផ្នែកស្មារតី និងថវិកាឲ្យកូនបានរៀនសូត្ររហូត ដល់ពេលបច្ចុប្បន្ននេះ។

- ឯកឧត្តម **លុយ ចន្ទណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានអនុញ្ញាតឲ្យយើងខ្ញុំមានឱកាសក្នុងការសរសេរនូវសារណានេះ។

- លោកសាស្រ្តាចារ្យ **ហោ សុវ័ណ្ណ** ជាសាស្រ្តាចារ្យណែនាំដែលបានឆ្លៀតឱកាសដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ផ្តល់នូវការណែនាំតម្រង់ទិសដល់រូបនាងខ្ញុំទាំងពីរនាក់ ក៏ដូចជាបានផ្តល់នូវឯកសារដែលពាក់ព័ន្ធ និងបានផ្តល់ជាអានុសាសន៍ល្អៗដើម្បីកែលំអរចំណុចខ្វះខាតទាំងឡាយ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។

- ថ្នាក់ដឹកនាំ សាស្រ្តាចារ្យ និងបុគ្គលិកសិក្សា នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំ។

- សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតថែមទៀត ចំពោះអ្នកនិពន្ធ និងអ្នកប្រាជ្ញ ព្រមទាំងទស្សនៈវិទូល្បីៗក្នុងពិភពលោក ដែលយើងខ្ញុំបានសិក្សាស្រាវពីស្នាដៃរបស់លោកក្នុងការបំពេញកិច្ចការស្រាវជ្រាវនាពេលកន្លងមកនេះ។

សូមមេត្តាទទួលនូវការថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះគុណឧបការដ៏ធំធេង និងមិនអាចបំភ្លេចបានអំពីយើងខ្ញុំ។

ជាទីបញ្ចប់នេះ រូបនាងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធិពរជ័យ សិរីបវរ ជូនដល់លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាស្រ្តាចារ្យទាំងអស់ សូមប្រកបបានដោយជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាបឋមនាងខ្ញុំ **ឆាយ លីនណា** និងនាងខ្ញុំ **សុខ សិរី** សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសសិស្ស និស្សិត ជាទីរាប់អានព្រមទាំងសាស្ត្រាចារ្យជាទីគោរព។

ក្នុងនាមជានិស្សិតដែលសិក្សានៅសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទស្តីពី **"នីតិវិធីព្រហ្មទណ្ឌក្នុងដំណាក់កាលអយ្យការ"** ដែលត្រូវបានទទួលគាំទ្រ និងជួយលើកទឹកចិត្តក៏ដូចជាការបង្ហាត់បង្ហាញកែតម្រូវពីសំណាក់ លោកសាស្ត្រាចារ្យ **ហោ សុវណ្ណា** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

រូបនាងខ្ញុំទាំងពីរនាក់បានសម្រេចជ្រើសរើសនូវប្រធានបទនេះមកធ្វើការស្រាវជ្រាវ និងចងក្រងឡើងជាសារណាបញ្ចប់ការសិក្សានេះគឺក្នុងគោលបំណងចូលរួមជាវិភាគទានដ៏សំខាន់នៅក្នុងដំណាក់កាលកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន ជាពិសេសពួកនាងខ្ញុំផ្ទាល់គឺមានបំណងចង់សិក្សាឲ្យបានស៊ីជម្រៅច្បាស់លាស់បន្ថែមទៀតអំពីខ្លឹមសារ និងអត្ថន័យនៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាក់ស្តែងគឺទាក់ទងទៅលើប្រធានបទនេះផ្ទាល់ ហើយក៏ទុកជាឯកសារសម្រាប់បំពេញបន្ថែមនូវតម្រូវការរបស់និស្សិតជំនាន់ក្រោយៗ និងជួយដល់អ្នកអានទាំងអស់ដែលមានគោលបំណងចង់សិក្សាស្រាវជ្រាវ ជំនាញវិជ្ជាជីវៈនីតិសាស្ត្រ។

ទោះបីជាមានការខិតខំស្រាវជ្រាវ និងត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយ ក៏ការសរសេរឡើងនូវសារណានេះប្រាកដជាអាចមាននូវចំណុចខ្វះខាតខាងផ្នែកខ្លឹមសារ និងអក្ខរាវិរុទ្ធជាក់ជាមិនខាន។ ដូច្នេះរូបនាងខ្ញុំទាំងពីរនាក់សង្ឃឹមថារាល់កំហុសឆ្គងទាំងឡាយណាដែលកើតមានឡើងក្នុងឯកសារនេះ នឹងទទួលបាននូវការអធ្យាស្រ័យ និងអភ័យទោសពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតអ្នកអានគ្រប់មជ្ឈដ្ឋានជាក់ជាមិនខាន។

រូបនាងខ្ញុំទាំងពីរនាក់សូមទទួលនូវការរិះគន់ និងកែតម្រូវក្នុងន័យស្ថាបនា ពីសំណាក់អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតអ្នកអានទាំងអស់គ្រប់ពេលវេលា។

ជាចុងបញ្ចប់នេះ រូបនាងខ្ញុំទាំងពីរនាក់សូមជូនពរ ដល់អស់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតអ្នកអានគ្រប់រូបឲ្យជួបប្រទះតែសេចក្តីសុខ ទទួលបាននូវភាពជោគជ័យក្នុងភារកិច្ច និងការសិក្សា ក៏ដូចជាអាចបំពេញនៅការងារដែលជាក្តីស្រមៃ និងសម្រេចបានតាមបំណងប្រាថ្នារបស់ខ្លួនទាំងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត។

# មាតិកា ទំព័រ

**សេចក្តីផ្តើម** ......... ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃស្ថាប័នអយ្យការ**

**ផ្នែកទី១៖ សមាសភាពនៃអយ្យការអមសាលាដំបូង** ......... ៦

ក. ព្រះរាជអាជ្ញា ......... ៦

ខ. ព្រះរាជអាជ្ញារង ......... ៦

គ. ក្រឡាបញ្ជី ......... ៧

**ផ្នែកទី២៖ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ** ......... ៧

ក. គោលការណ៍ឯកភាព ......... ៨

ខ. គោលការណ៍អវិភាគ ......... ៩

គ. គោលការណ៍ឯករាជ្យ ......... ៩

ឃ. គោលការណ៍មិនទទួលខុសត្រូវ ......... ១០

ង. គោលការណ៍មិនអាចប្តឹងជំទាស់ ......... ១១

**ផ្នែកទី៣៖ សមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា** ......... ១១

ក. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ......... ១១

ខ. តួនាទីរបស់ព្រះរាជអាជ្ញា ......... ១២

គ. ភារកិច្ចរបស់ព្រះរាជអាជ្ញា ......... ១៣

ឃ. អំណាចរបស់ព្រះរាជអាជ្ញា ......... ១៣

**ជំពូកទី២**

**ការចោទប្រកាន់របស់ព្រះរាជអាជ្ញា**

**ផ្នែកទី១៖ ការបើកការស៊ើបសួរ** ......... ១៨

ក. លក្ខខណ្ឌដែលនាំឱ្យមានការស៊ើបសួរ ......... ១៨

ខ. នីតិវិធីនៃការបើកការស៊ើបសួរ ......... ២០

គ. ទម្រង់ចាំបាច់ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ......... ២១

ឃ. អានុភាពនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ......... ២២

**ផ្នែកទី២៖ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់**.....២៣

ក. លក្ខខណ្ឌដែលនាំឱ្យមានការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់.....២៣

ខ. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់.....២៥

គ. ទម្រង់នៃដីកាបញ្ជូនរឿងទៅជម្រះផ្ទាល់.....២៦

ឃ. អានុភាពនៃការបញ្ជូនរឿងទៅជម្រះផ្ទាល់.....២៦

**ផ្នែកទី៣៖ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**.....២៧

ក. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម.....២៧

ខ. អានុភាពនៃការបង្គាប់ឱ្យចូលខ្លួនភ្លាម.....២៩

**ជំពូកទី៣**

**ការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា**

**ផ្នែកទី១៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**.....៣២

ក. នត្ថិភាពនៃបទល្មើស.....៣២

ខ. មូលហេតុគតិយុត្ត.....៣៣

គ. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍.....៣៤

**ផ្នែកទី២៖ នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**.....៣៥

ក. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ.....៣៥

ខ. ទម្រង់ការនៃការតម្កល់រឿងទុកឥតចាត់ការ.....៣៥

គ. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ.....៣៥

**ផ្នែកទី៖៣ យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ**.....៣៦

ក. ការលើកយកប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា.....៣៦

ខ. បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍.....៣៦

គ. អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ.....៣៦

ឃ. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ.....៣៧

**សន្និដ្ឋាន និងអនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ជាការពិតណាស់សន្តិសុខ សណ្តាប់ធ្នាប់ យុត្តិធម៌ និងតម្លាភាព គឺជាធាតុផ្សំយ៉ាងសំខាន់ក្នុងការជម្រុញឲ្យប្រទេសជាតិមួយពោរពេញទៅដោយការអភិវឌ្ឍ និងប្រកបដោយភាពជឿនលឿនទៅបានលើគ្រប់វិស័យ។ ធាតុផ្សំសំខាន់ៗក្នុងការអភិវឌ្ឍប្រទេសជាតិដែលបានរៀបរាប់ដូចខាងលើ គឺទាមទារឲ្យប្រទេសជាតិនោះត្រូវធ្វើការបង្កើតឡើងនូវវិធានការច្បាប់ ក៏ដូចជាបទដ្ឋានគតិយុត្តិផ្សេងៗ ព្រមទាំងត្រូវធានាឲ្យបាននូវប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់ក៏ដូចជាលខិតបទដ្ឋានគតិយុត្តដែលបានបង្កើតឡើងនោះផងដែរ។ ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវតែប្រាកដថាបានអនុត្តបានយ៉ាងត្រឹមត្រូវ មិនមានភាពលំអៀង និងត្រូវតែឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស ជាពិសេសគឺជនដែលងាយរងគ្រោះដូចជាប្រជាជនស្លូតត្រង់ជាដើម។ ដើម្បីពង្រឹងនៅតម្លាភាពក្នុងការអនុវត្តច្បាប់ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តទាំងនោះពោលគឺត្រូវតែមាននូវស្ថាប័នតុលាការឯករាជ្យ និងយុត្តិធម៌។ ក្រឡេកមកមើលប្រព័ន្ធយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាយើង គឺអាចសង្កេតបានថាមានភាពផ្លាស់ប្តូរទៅតាមរបបគ្រប់គ្រងប្រទេសតាមសម័យកាលនីមួយៗ ចំពោះការគ្រងប្រព័ន្ធនៅក្នុងសម័យទំនើបបច្ចុប្បន្នប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជាត្រូវបានបែងចែកជាជាន់ថ្នាក់ ហើយការបែងចែកប្រព័ន្ធយុត្តិធម៌ជាជាន់ថ្នាក់បែបនេះគឺធ្វើឡើងនៅក្នុងគោលបំណងមួយដើម្បីសម្រួលដល់ បញ្ហាដែលពាក់ព័ន្ធ និងបទល្មើសព្រហ្មទណ្ឌ។ អ្នកតាក់តែងឡើងនូវវិធានច្បាប់ បានតាក់តែងនូវវិធានដែលមានសម្ថកិច្ចនៅតាមតុលាការ និងការអនុវត្តទៅតាមលំហូរនៃនីតិវិធី ដែលបានបញ្ញត្តិទុកជាស្រេចក្នុងច្បាប់ការពារសិទ្ធិ និងផលប្រយោជន៍ទាំងជនរងគ្រោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងជនដែលត្រូវបានទទួលរងក្នុងការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ។

ចំពោះប្រទេសកម្ពុជាច្បាប់ដែលត្រូវបានតាក់តែងសម្រាប់យកមកប្រើប្រាស់ ជាវិធានការចម្បងលើការអនុវត្តរបស់តុលាការព្រហ្មទណ្ឌក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌឲ្យស្របទៅតាមនីតិវិធីជាក់លាក់នោះគឺ **ក្រមនីតិវិធីព្រហ្មទណ្ឌ** ដែលក្រមនេះត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។ ការចងក្រងឡើងនូវក្រមនីតិវិធីព្រហ្មទណ្ឌនេះ គឺត្រូវបានធ្វើឡើងអស់រយៈពេលជាង១០ឆ្នាំ។ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះដែរ ការដោះស្រាយ រឿងក្តីព្រហ្មទណ្ឌគឺត្រូវបានបែងចែកជាបួនដំណាក់កាលធំៗគឺ ដំណាក់កាលនៃការស៊ើបអង្កេត ដំណាក់កាលនៃការចោទប្រកាន់ តំណាក់កាលនៃការស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះ។ យើងឃើញថាដំណាក់កាលទាំងបួន គឺជាធាតុដ៏សំខាន់ដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងមិនអាចខ្វះបាន។ ដោយឡែកដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយដ៏សំខាន់មុននឹងចូលដល់ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ ដំណាក់កាលនៃការចោទប្រកាន់នេះ គឺត្រូវបានធ្វើឡើងដោយសំណាក់ស្ថាប័ន

អយ្យការដែលជាស្ថាប័នតំណាងឲ្យអង្គការនីតិប្រតិបត្តិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ និងអមសាលាជម្រះក្ដីដោយមានតួនាទី ជាម្ចាស់បណ្ដឹងអាជ្ញា ជាអ្នកធ្វើការចោទប្រកាន់នៅរឿងក្ដីព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការធ្វើការអនុវត្តច្បាប់។ តាមបទបញ្ញត្តិ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១៣១ បានចែងថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា"។ មាត្រានេះបានចង់មានន័យថាព្រះរាជអាជ្ញា គឺជាភាគីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌមានតួនាទីតំណាងឲ្យរដ្ឋ តំណាងឲ្យសង្គម និងការពារផលប្រយោជន៍ទូទៅជូនដល់សាធារណៈជន និងមានតួនាទីធ្វើបណ្ដឹងចោទទៅតុលាការឲ្យផ្ដន្ទាទោសចំពោះជនដែលប្រព្រឹត្តិបទល្មើស។ ជាក់ស្ដែងនៅពេលដែលមានរឿងក្ដីព្រហ្មទណ្ឌកើតមានឡើងមានតែស្ថាប័នអយ្យការតែមួយគត់ដែលមានព្រះរាជអាជ្ញាជាអ្នកតំណាងក្នុងការធ្វើបណ្ដឹងអាជ្ញា និងតំណាងឲ្យផលប្រយោជន៍សង្គមទាំងមូល។ ព្រះរាជអាជ្ញាជាអ្នកធ្វើការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបញ្ជូនមកតាម រយៈពាក្យបណ្ដឹងរបស់ជនរងគ្រោះផ្ទាល់ និងពាក្យបណ្ដឹងដែលបញ្ជូនមកតាមរយៈ មន្ត្រីនគរបាលយុត្តិធម៌។ ប្រសិនបើយើងពិនិត្យមើលឲ្យស៊ីជម្រៅក្រៅពីការចោទប្រកាន់របស់ព្រះរាជអាជ្ញានៅក្នុងរឿងក្ដីព្រហ្មទណ្ឌ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានផ្ដល់ជម្រើសដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងក៏ដូចជាប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់។ ដោយហេតុថាមិនមែនគ្រប់បទល្មើស ឬអង្គហេតុដែលកើតឡើងគឺសុទ្ធតែត្រូវធ្វើការចោទប្រកាន់បានទាំងអស់នោះទេ ពោលគឺក្រមនីតិវិធីព្រហ្មទណ្ឌបានផ្ដល់សិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការសម្រេចចាកម្ដល់រឿងទុកឥតចាត់ការ ឬសម្រេចធ្វើបណ្ដឹងសុំចោទប្រកាន់ធ្វើយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះដើម្បីស្វែងរកឲ្យឃើញអំពីអត្ថិភាពនៃបទល្មើស និងដើម្បីផ្ដន្ទាទោសជនល្មើសឲ្យស្របទៅតាមច្បាប់។

ជាគោលការណ៍នៅក្នុងស្ថាប័នអយ្យការ គឺមានព្រះរាជអាជ្ញាដែលមានមុខងារ និងតួនាទីខុសគ្នាទៅតាមសាលាជម្រះក្ដី។ ការតាក់តែងឡើងនៅសារណានេះគឺ នាងខ្ញុំទាំងពីររូបបានតាក់តែងឡើងដោយផ្ដោតតែចំពោះអង្គការអយ្យការអមសាលាដំបូងប៉ុណ្ណោះ ពោលគឺបកស្រាយអំពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាដែលជាសិទ្ធិរបស់អង្គការអយ្យការអមសាលាដំបូង ដោយផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ចំពោះសារៈសំខាន់ក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះ បានផ្ដល់ឲ្យយល់កាន់តែច្បាស់អំពីនីតិវិធីនៃការចោទប្រកាន់ និងការវិភាគវែកញែកឲ្យកាន់តែច្បាស់ទៅលើនីតិវិធីនីមួយៗ។ ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏បានឆ្លុះបញ្ចាំងអំពីសារៈសំខាន់របស់ព្រះរាជអាជ្ញាក្នុងការចូលរួមស្វែងរកយុត្តិធម៌ក្នុងរឿងក្ដីព្រហ្មទណ្ឌជូនដល់ជនរងគ្រោះក្នុងរឿងក្ដីព្រហ្មទណ្ឌផងដែរ។

លើសពីនេះការស្រាវជ្រាវទៅលើប្រធានបទនេះក៏បានធ្វើឲ្យយើងយល់ និងស្គាល់កាន់តែច្បាស់អំពីស្ថាប័នអយ្យការផងដែរថាតើស្ថាប័ននេះមានសមាសភាព តួនាទី ភារកិច្ច និងអំណាចយ៉ាងដូចម្ដេចខ្លះ? តើអង្គការអយ្យការដែលមានព្រះរាជអាជ្ញាជាតំណាងនោះ អាចប្រើអំណាចក្នុងការចោទប្រកាន់ និងអំណាចទៅលើចំណាត់ការលើបណ្ដឹងដែលខ្លួនទទួលបានដោយជាក់ស្ដែងតាមនីតិវិធីអ្វីខ្លះ? ហើយមានមូលហេតុអ្វីខ្លះដែលធ្វើឲ្យព្រះរាជអាជ្ញាអាចសម្រេចមិនចោទប្រកាន់បាន?

ដើម្បីងាយស្រួលក្នុងការឆ្លើយតបទៅកាន់បញ្ហាចោទទាំងអស់នោះ សារណានេះត្រូវបានសរសេរឡើងដោយបែងចែកជាបីជំពូក។ គួរបញ្ជាក់ផងដែរថាជំពូកនីមួយៗ បានបញ្ជាក់ពីខ្លឹមសាររបស់ប្រធានបទទាំងស្រុង។ ជំពូកទី១ "សញ្ញាណទូទៅនៃស្ថាប័នអយ្យការ" ក្នុងជំពូកនេះគឺបានរៀបរាប់អំពី៖ សមាសភាព គោលការណ៍ តួនាទី ភារកិច្ច និងអំណាចរបស់ស្ថាប័នអយ្យការ។ ជំពូកទី២ "ការចោទប្រកាន់"។ ចំពោះជំពូកទី២នេះគឺយើងនឹងរៀបរាប់អំពីការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម និងជំពូកទី៣ "ការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា" ក្នុងជំពូកចុងក្រោយនេះគឺបានរៀបរាប់អំពី៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ នីតិវិធី ទម្រង់ការ និងអនុភាពនៃការតម្កល់រឿងទុកឥតចាត់ការ និងយន្តការជម្រុញឲ្យមានការចោទប្រកាន់ឡើងវិញ។

# ជំពូកទី១
# សញ្ញាណទូទៅនៃស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ គឺជាស្ថាប័នតំណាងរបស់អង្គការនីតិប្រតិបត្តិដើម្បីការពារសណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងផលប្រយោជន៍ទូទៅ។ ស្ថាប័នអយ្យការរួមមាន អយ្យការអមសាលាក្តីជាន់ទាប និងមហាអយ្យការ ត្រូវបានបង្កើតឡើងនៅអមជាមួយនឹងសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅក្នុងប្រទេស។ តាមមាត្រា៨ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានចែងថា នៅអមសាលាដំបូងត្រូវមានអង្គការមួយ ហៅថា **អយ្យការអមសាលាដំបូង**។ នៅអមសាលាឧទ្ធរណ៍ត្រូវមានអង្គការមួយ ហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍។ នៅអមតុលាការកំពូលត្រូវមានអង្គការមួយ ហៅថាមហាអយ្យការអមតុលាការកំពូល។ តំណាងអយ្យការទាំងអស់ត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីផ្សេងៗទៀតដែលច្បាប់បានកំណត់។ វត្តមានរបស់ស្ថាប័នអយ្យការដែលអមនៅតាមសាលាជម្រះក្តី គឺដើម្បីធានាឲ្យបានថា ដំណើរការនូវរឿងក្តីព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តិឡើងដោយភាពយុត្តិធម៌ និងដើម្បីការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌមួយផងដែរ។ ទាំងអយ្យការអមសាលាជម្រះក្តីជាន់ទាបដែលជាអយ្យការអមសាលាដំបូង និងមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ក្នុងនោះរួមមានមហាអយ្យការអមសាលាឧទ្ធរណ៍ និងមហាអយ្យការអមតុលាការកំពូល គឺសុទ្ធតែត្រូវបានកំណត់មុខការ ក៏ដូចជាតួនាទីខុសៗគ្នាទៅតាមសាលាជម្រះក្តីនីមួយៗ ដូចដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ អយ្យការអមសាលាជម្រះក្តីជាន់ទាប ឬអយ្យការអមសាលាដំបូងតំណាងរបស់អង្គការនីតិប្រតិបត្តិដែលមានមុខងារក្នុងការធ្វើបណ្តឹងអាជ្ញា និងជាអ្នកសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។[1]

អយ្យការអមសាលាដំបូងមានមុខងារចំបងក្នុងការធ្វើបណ្តឹងអាជ្ញា ឬជាម្ចាស់នៃបណ្តឹងអាជ្ញា មានន័យថា ជាអ្នកធ្វើការចោទប្រកាន់នៅពេលមានអំពើទាំងឡាយណាដែលបង្កើតជាភាពចលាចលនៅក្នុងសង្គម ដែលអំពើនោះត្រូវបានកំណត់នៅក្នុងបទបញ្ញត្តិទុកមុនថាជាបទល្មើសព្រហ្មទណ្ឌ ហើយស្នើរសុំឲ្យយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះអនុវត្តច្បាប់ថែមទៀត។ យើងអាចនិយាយបានថាអយ្យការអមសាលាដំបូង ជាយុត្តាធិការដ៏សំខាន់នៅក្នុងដំណើរនៃការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ដោយសារតែអង្គការមួយនេះជាកត្តាដែលជម្រុញឲ្យរឿងក្តីព្រហ្មទណ្ឌមួយអាចដំណើការទៅមុខបាន ដើម្បីឈានទៅដល់ការបង្ក្រាបបទល្មើស និង

[1] មាត្រា៣០ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

ការផ្តន្ទាទោសដល់ជនល្មើសដែលបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ និងរកនូវយុត្តិធម៌ជូនដល់ជនរងគ្រោះដោយសារបទល្មើសព្រហ្មទណ្ឌផងដែរ។

ជាបន្តទៅនេះ មុននឹងឈានទៅដល់ការស្វែងយល់អំពីការចោទប្រកាន់ដែលជាតួនាទីចំបងរបស់អង្គការអយ្យការ យើងគួរគប្បីស្វែងយល់ជាមុនអំពីសញ្ញាញទូទៅនៃស្ថាប័ននេះជាមុនផងដែរ។ តើស្ថាប័ននេះត្រូវបានបំពេញតួនាទីដោយនរណា? តើស្ថាប័ននេះត្រូវគោរពនូវគោលការណ៍សំខាន់ៗរបស់ខ្លួនអ្វីខ្លះ? តើសមាសភាពនៃអង្គការនេះមានសមត្ថកិច្ច តួនាទី ភារកិច្ច និងអំណាចយ៉ាងដូចម្តេច? ហេតុនេះហើយ ដើម្បីបកស្រាយនូវសំណួរដូចដែលមានចោទទាំងអស់នេះ យើងខ្ញុំនិងធ្វើការបកស្រាយចំពោះខ្លឹមសារនៃចម្លើយរបស់សំណួរខាងលើជាបីផ្នែកជាបីផ្នែកគឺ៖

**ផ្នែកទី១៖ សមាសភាពនៃអយ្យការ**

**ផ្នែកទី២៖ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ**

**ផ្នែកទី៣៖ សម្ថកិច្ច តួនាទី ភារកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា**

## ផ្នែកទី១៖ សមាសភាពនៃអយ្យការអមសាលាដំបូង

តាមមាត្រា២៩ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលា ឆ្នាំ២០១៥ ការបានចែងអំពីសមាសភាពអយ្យការអមសាលាដំបូងដែលក្នុងនោះរួមមាន៖ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រលាបញ្ជី និងមន្ត្រី រដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ដែលនៅបម្រើការងារនៅអយ្យការអមសាលាដំបូង។

### ក. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា គឺជាប្រមុខដឹកនាំរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្តនីមួយៗនៃប្រទេសកម្ពុជា។ នៅរាល់អយ្យការអមសាលាដំបូងនីមួយៗត្រូវបានដឹកនាំដោយព្រះរាជអាជ្ញាចំនួនមួយរូប។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ដែលបានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ក៏ដូចជាបទប្បញ្ញត្តិនានាដែលនៅជាធរមាន ក្នុងការធ្វើសកម្មភាពរបស់ខ្លួនក្នុងនាមជាតំណាងអយ្យការ។

ព្រះរាជអាជ្ញាមានតួនាទីក្នុងការទទួលខុសត្រូវលើការប្រព្រឹត្តទៅទាំងមូលរបស់អង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមានខ្លួនជាអ្នកដំណាង ដែលជាហេតុនាំឱ្យព្រះរាជអាជ្ញាត្រូវទទួលខុសត្រូវចំពោះការងាររបស់ខ្លួនផង និងការងាររបស់ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនទាំងអស់ផងដែរ។

### ខ. ព្រះរាជអាជ្ញារង

អយ្យការអមសាលាដំបូងត្រូវដឹកនាំដោយព្រះរាជអាជ្ញា០១ (មួយ) រូប និងអមដោយព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៃសាលាដំបូងជាតំណាងឱ្យអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ[2]។ មានន័យថានូវរាល់អយ្យការអមសាលាដំបូងរាជធានី-ខេត្តនីមួយៗត្រូវមានព្រះរាជអាជ្ញាតែមួយរូបប៉ុណ្ណោះដែលជាតំណាង ប៉ុន្តែអាចមានព្រះរាជអាជ្ញារងជាច្រើនរូបដែលមិនអាចកំណត់ចំនួនមួយជាក់លាក់បានឡើយ ពោលគឺអាស្រ័យទៅតាមតម្រូវការការងារ និងភាពចាំបាច់របស់ស្ថាប័ន។ មាត្រា៣១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានចែងថា "ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ដែលនៅក្នុងដែនដីសម្តកិច្ចរបស់ខ្លួនទាំងអស់។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែងការងារដល់ព្រះរាជអាជ្ញារងទាំងអស់។ មាត្រានេះមានន័យថាតួនាទីរបស់ព្រះរាជអាជ្ញារង គឺត្រូវបានចាត់តាំង និងបែងចែកដោយព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ[3]។

[2] មាត្រា៣១ កថាខណ្ឌទី១ ដល់កថាកណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

[3] មាត្រា៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

តាមមាត្រា៣១ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានចែងថា "នូវរាល់សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារងត្រូវតែបញ្ជូនទៅឱ្យ ព្រះរាជអាជ្ញាត្រួតពិនិត្យជាមុនសិននៅមុនពេលសវនាការ។ ក្នុងករណីដែលព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាមព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំង ខ្លួនឯងតែម្តងឱ្យធ្វើជាតំណាងអយ្យការក្នុងសវនាការនៃសាលាដំបូង"។ តាមរយៈមាត្រានេះបានសបញ្ជាក់ថាថ្វីត្បិតតែព្រះរាជអាជ្ញារងមានសិទ្ធិក្នុងការប្រើប្រាស់សិទ្ធិអំណាចទាំងអស់របស់ព្រះរាជអាជ្ញាប៉ុន្តែសិទ្ធិអំណាចមួយចំនួននោះត្រូវតែស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យ និងសម្រេចរបស់ព្រះរាជអាជ្ញា។

### គ. ក្រឡាបញ្ជី

ក្រឡាបញ្ជី គឺជាអ្នកបច្ចេកទេសផ្នែកនីតិវិធីដែលជួយសម្រួលដល់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងសកម្មភាពសាលាជម្រះក្តីទៅតាមលក្ខខណ្ឌដែលមាននៅក្នុងប្បញ្ញត្តិច្បាប់ ឬបទបញ្ជាដែលមានជាធរមាន។ ក្រឡាបញ្ជីគឺជាសមាសភាពមួយដែលអនុវត្តមុខងាររបស់ខ្លួននៅតាមសាលាក្តីគ្រប់ជាន់ថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងអយ្យការអមសាលាដំបូងគឺមានក្រឡាបញ្ជីជាច្រើនរូបដែលជាលេខាធិការផ្ទាល់របស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងក្នុងការបំពេញការងារ ទាំងផ្នែករដ្ឋបាន និងចំណាត់ការលើសំណុំរឿងឱ្យកាន់តែមានភាពងាយស្រួល។ ក្រឡាបញ្ជីស្ថិតនៅក្រោមការបង្គាប់បញ្ជា និងដឹកនាំរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដែលខ្លួនស្ថិតនៅអមសម្រាប់កិច្ចការផ្នែកយុត្តាធិការ ហើយបំពេញមុខងារក្នុងរឿងរដ្ឋបាល និងចំណាត់ការទៅលើសំណុំរឿងដូចជា៖ ការធ្វើកំណត់ហេតុ ស្តាប់ចម្លើយ ការធ្វើសេចក្តីព្រាងដីកា ឬសំណុំលិខិតផ្សេងៗសម្រាប់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ការចុះលេខសំណុំឯកសារ រក្សាទុកនូវសំណុំរឿង និងស្រាវជ្រាវរកនូវឯកសារផ្សេងៗទៀត។ល។ ចំពោះសេចក្តីសម្រេច ក៏ដូចជាសេចក្តីសន្និដ្ឋានណាមួយដែលជាសម្ថកិច្ចរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឱ្យបំពេញបានឡើយ។

## ផ្នែកទី២៖ គោលការណ៍សំខាន់ៗរបស់អង្គការអយ្យការ

ជាការពិតណាស់ អង្គការអយ្យការគឺជាស្ថាប័នមួយដែលបង្កើតឡើងក្នុងគោលបំណង ធានាឲ្យបាននូវដំណើការនៃរឿងក្តីព្រហ្មទណ្ឌមួយឱ្យប្រព្រឹត្តិឡើងដោយភាពយុត្តិធម៌ ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងដំណើការរឿងក្តីព្រហ្មទណ្ឌ នឹងធានាឲ្យបាននូវតម្លាភាព សន្តិសុខ សង្គម ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈផងដែរ។ ដើម្បីជាកត្តាជម្រុញដល់ការប្រព្រឹត្តទៅនូវរាល់ការបំពេញកិច្ចការរបស់អង្គការអយ្យការឱ្យប្រកបបានដោយប្រសិទ្ធិភាពខ្ពស់ច្បាប់ បានប្បញ្ញត្តិអំពីគោលការណ៍សំខាន់ៗមួយចំនួនឡើងសម្រាប់ស្ថាប័ននេះផ្ទាល់។ គោលការណ៍សំខាន់ៗដែលអង្គការអយ្យការត្រូវគោរពតាមរួមមាន៖ គោលការណ៍ឯកភាព គោលការណ៍អវិភាគ

គោលការណ៍ឯករាជ្យ គោលការណ៍មិនទទួលខុសត្រូវ និងគោលការណ៍មិនអាចប្ដឹងជិតចិត្ត។ គោលការណ៍ដែលបានលើកឡើងខាងលើសុទ្ធសឹងតែជាគោលការណ៍បានច្បាប់បានប្បញ្ញត្តិទុកជាធរមាន។

## ក. គោលការណ៍ឯកភាព

គោលការណ៍ឯកភាព ឬហៅបានម៉្យាងទៀតថាជាគោលការណ៍ឋានានុក្រម ដែលតាមគោលការណ៍នេះព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន4។ តាមគោលការណ៍នេះផងដែររាល់តំណាងអយ្យការត្រូវតែគោរពទៅតាមបទបញ្ជា និងអនុវត្តមុខងាររបស់ខ្លួនតាមរយៈការបង្គាប់របស់អ្នកដែលមានឋានុក្រមខ្ពស់ជាង។ ឋានានុក្រមនៃអង្គការអយ្យការត្រូវបានកំណត់ឡើងដូចជា៖

### ១. រដ្ឋមន្រ្តីក្រសួងយុត្តិធម៌

តាមមាត្រា៧៥ កថាខណ្ឌទី១ វាយ្យខណ្ឌទី២ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានចែងថា "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់"។ ក្នុងវាយ្យខណ្ឌនេះគឺមានន័យថារដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌គឺជានាយដែលមានឋានុក្រមខ្ពស់ជាងគេ ហើយអាចធ្វើអធិបញ្ញាជាលិខិតណែនាំជាលាយលក្ខណ៍អក្សរទៅគ្រប់ស្ថាប័នអយ្យការ ពោលគឺទាំងមហាអយ្យការអមតុលាការកំពូល មហាអយ្យការអមសាលាឧទ្ធរណ៍ និងអយ្យការអមសាលាដំបូង ដោយមានអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ជាសេនាធិការឱ្យរដ្ឋមន្ត្រីជាអ្នកធ្វើកិច្ចការនេះ។

### ២. អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយកថានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។ តាមឋានានុក្រមនៃតុលាការកំពូល រាល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃស្ថាប័នមហាអយ្យការអមតុលាការកំពូលត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវ និងការដឹកនាំពីសំណាក់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

### ៣. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការ

[4] មាត្រា៧៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

ទទួលខុសត្រូវរបស់នាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍ គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

### ៤. ព្រះរាជអាជ្ញាអមសាលាដំបូង

ព្រះរាជអាជ្ញាអមសាលាដំបូងគឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៅក្នុងអយ្យការអមសាលាដំបូងត្រូវស្ថិតនៅក្រោមការដឹកនាំ និងទទួលខុសត្រូវពីសំណាក់ព្រះរាជអាជ្ញាអមសាលាដំបូងដែលជានាយឋានានុក្រមរបស់ខ្លួន។

## ខ. គោលការណ៍អវិភាគ

មាត្រា៧៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានបញ្ញត្តិអំពីគោលការណ៍អវិភាគរបស់អង្គការអយ្យការថា ជាគោលការណ៍ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្តីណាមួយមានកាតព្វកិច្ចរួមក្នុងមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះ តំណាងអយ្យការជាច្រើនរូបអាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។ នៅក្នុងមាត្រានេះ ចង់បញ្ជាក់ថានៅរាល់កិច្ចការ ឬលិខិតស្នាមដែលចេញដោយតំណាងរបស់អគ្គការអយ្យការណាមួយគឺ មានតម្លៃដូចទៅនិងលិខិតស្នាមដែលចេញដោយអង្គការអយ្យការទាំងមូល។ តាមគោលការណ៍អវិភាគនេះ យើងឃើញថាទោះបីជានៅពេលដែលមានវត្តមាន ឬអវត្តមាននៃនាយឋានានុក្រមតាមស្ថាប័នអយ្យការណាមួយក៏ដោយ ក៏ខ្លួនអាចមានសិទ្ធិក្នុងការចាត់តាំងនូវតំណាងអយ្យការណាម្នាក់ ក្នុងចំណោមតំណាងអយ្យការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការទទួលរបស់ខ្លួនឱ្យទៅបំពេញកិច្ចការនោះជំនួសខ្លួនបាន។ ពោលគឺចំពោះមហាអយ្យការអមតុលាការកំពូលទោះបីជាមានវត្តមាន ឬអវត្តមានរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមនៃមហាអយ្យការអមតុលាកំពូល ខ្លួនមានសិទ្ធិចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាឱ្យធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់ខ្លួនបានដែលមានលក្ខណៈដូចគ្នាទៅនិងមហាអយ្យការអមសាលាឧទ្ធរណ៍ដែរ។ ចំណែកឯអយ្យការអមសាលាដំបូងវិញទោះបីជាមានវត្តមាន ឬអវត្តមាននៃព្រះរាជអាជ្ញាក៏ដោយ ព្រះរាជអាជ្ញារងគឺធ្វើការក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

## គ. គោលការណ៍ឯករាជ្យ

អង្គការអយ្យការ គឺជាអង្គការឯករាជ្យដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ។ សាលាជម្រះក្តីនេះ គ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ។ ទោះបីនៅក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេច

របស់ខ្លួន យកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ មានន័យថា ថ្វីត្បិតតែអង្គការអយ្យការស្ថិតនៅអម សាលាជម្រះក្តីក៏ពិតមែន ប៉ុន្តែអង្គការនេះមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ពោលគឺអង្គការអយ្យការជាអង្គការមួយដែលឯករាជ្យ។ លើសពីនេះទៅទៀតនៅពេលដែលព្រះរាជអាជ្ញាមាន កំហុសឆ្គង នៅក្នុងការបំពេញមុខងារសាលាជម្រះក្តីមិនមានអំណាចក្នុងការចេញនូវសេចក្តីសម្រេចណាមួយ របស់ខ្លួន ឬធ្វើការស្តីបន្ទោសទៅលើព្រះរាជអាជ្ញាឡើយ ក៏ប៉ុន្តែខ្លួនអាចលើកយកសំណើររបស់ខ្លួនទៅកាន់នាយ ឋានានុក្រមរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើចំណាត់ការលើកំហុសឆ្គងដែលកើតមានឡើងនោះ។ ដែលការអនុវត្ត បែបនេះ គឺបានអនុវត្តទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ ទាំងក្នុងរឿងក្តីផ្សេងៗទៀត5។

## ឃ. គោលការណ៍មិនទទួលខុសត្រូវ

ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាប្រើសិទ្ធិក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋក្នុងការធ្វើការ ចោទប្រកាន់ទៅលើសកម្មភាព ឬអង្គហេតុណាដែលខ្លួនយល់ឃើញជាបទល្មើសព្រហ្មទណ្ឌធ្វើឱ្យប៉ះពាល់ដល់ ប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គម។ តាមគោលការណ៍ច្បាប់ ការចោទប្រកាន់របស់ព្រះរាជអាជ្ញាគឺ អាចត្រូវបានទទួលនូវការច្រាលចោល ពីសំណាក់ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះក្នុងករណីដែលអង្គហេតុ នៃបទល្មើសដែលតំណាងអយ្យការបានចោទប្រកាន់នោះបានពិនិត្យទៅឃើញថា មិនមែនជាបទល្មើសព្រហ្ម ទណ្ឌ ឬគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនជាប់ចោទ ឬជនត្រូវចោទជាអាទិ៍។ ប្រសិនបើក្នុង ករណីដែលមានការច្រានចោលការចោទប្រកាន់ពីសំណាក់ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះដែលមានមូល ហេតុដូចទៅនិងការរៀបរាប់ខាងលើ តាមគោលការណ៍មិនទទួលខុសត្រូវនេះ ព្រះរាជអាជ្ញាមិនតម្រូវឱ្យទទួល បាននូវការទទួលខុសលើរាល់ការខូចខាតដែលចេញពីសេចក្តីសម្រេចលើការចោទប្រកាន់របស់ខ្លួនទៅលើភាគី នៃរឿងក្តី ជាពិសេសជនជាប់ចោទនៅក្នុងសំណុំរឿងនោះឡើយ។ អ្វីដែលគួរឱ្យកត់សម្គាល់នៅក្នុងគោលការណ៍ នេះផ្ទាល់គឺ មិនបានការពារនូវរាល់តំណាងអយ្យការណាម្នាក់ពីកំហុសបទល្មើសព្រហ្មទណ្ឌ ដែលខ្លួនបាន ប្រព្រឹត្តនៅក្នុងករណីដែលការប្រព្រឹត្តិនូវបទល្មើសនោះកើតចេញពី ឆន្ទៈទុច្ចរិតក្នុងការបំពេញមុខងាររបស់ខ្លួន បានទេ។ ឧទាហរណ៍៖ សកម្មភាពដែលតំណាងអយ្យការមួយរូបណាបានទទួលនូវសំណូក ដើម្បីសម្រេច ក្នុងការមិនធ្វើនូវការចោទប្រកាន់ជាអាទិ៍។ ដូច្នេះហើយយើងឃើញថាព្រះរាជអាជ្ញា ក៏ដូចជាតំណាងអយ្យការ គ្រប់រូបត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌនៅពេលដែលខ្លួនបានប្រព្រឹត្ត បទល្មើសព្រហ្មទណ្ឌណាមួយ នៅលើកិច្ចចោទប្រកាន់របស់គាត់ដូចដែលច្បាប់បានបញ្ញត្តិទុក។

[5] មាត្រា៧៥ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

### ខ. គោលការណ៍មិនអាចប្តឹងជំទាស់ចិត្ត

តាមគោលការណ៍នៃច្បាប់ ប្រសិនបើភាគីម្ខាងណានៅក្នុងរឿងក្តីយល់ឃើញថាសមាសភាពជំនុំជម្រះមិនអាចការរក និងផ្តល់ជូននូវយុត្តិធម៌ដល់ខ្លួនបានដោយសារមូលហេតុណាមួយ ភាគីនោះអាចធ្វើការស្នើសុំដើម្បីប្តូរសមាសភាពជំនុំជម្រះនោះបាន។ ប៉ុន្តែនៅក្នុងករណីសំនុំរឿងព្រហ្មទណ្ឌនូវរាល់ភាគីក្នុងរឿងក្តីណាក៏មិនអាចធ្វើការប្តឹងជំទាស់ចិត្តចំពោះព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងដែលជាតំណាងនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្តបាននោះទេ ទោះបីជានៅក្នុងករណីដែលតំណាងអយ្យការជាសាច់ញ្ញាតិ ឬជាប់ពាក់ព័ន្ធទៅនិងផលប្រយោជន៍របស់ភាគីបណ្តឹងម្ខាងណាក៏ដោយ។ មូលហេតុដែលភាគីក្នុងរឿងក្តីព្រហ្មទណ្ឌមិនអាចធ្វើការប្តឹងជំទាស់ចិត្តចំពោះតំណាងអយ្យការបាន គឺដោយហេតុថា ការធ្វើឡើងនូវរាល់ការចោទប្រកាន់របស់តំណាងអយ្យការគឺធ្វើឡើងក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ មិនមែនជាការចោទប្រកាន់ដើម្បីផលប្រយោជន៍របស់ខ្លួនផ្ទាល់នោះទេ។ ការចោទប្រកាន់របស់តំណាងអយ្យការនោះផងដែរមិនបានមានន័យថាបុគ្គលដែលត្រូវបានធ្វើការចោទប្រកាន់ ឬជនជាប់ចោទនោះ និងត្រូវទទួលនូវការផ្តន្ទាទោសដូចទៅនិងការចោទប្រកាន់របស់តំណាងអយ្យការឡើយ។ ដោយសារមូលហេតុទាំងអស់នេះហើយទើបព្រះរាជអាជ្ញា ក៏ដូចជាតំណាងអយ្យការមិនត្រូវបានចាត់ទុកថាជាកម្មវត្ថុនៃបណ្តឹងជំទាស់ចិត្តបានឡើយ។

## ផ្នែកទី៣៖ សមត្ថកិច្ច តួនាទី ភារៈកិច្ច និងអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា គឺជាអ្នកតំណាង និងជាអ្នកដឹកនាំនៅក្នុងអង្គការអយ្យការអមសាលាដំបូង។ ដើម្បីធានាដល់ប្រសិទ្ធភាពក្នុងការបំពេញនូវរាល់កិច្ចការនៅក្នុងដំណើររឿងក្តីព្រហ្មទណ្ឌនីមួយៗ ក៏ដូចជាដើម្បីជៀសវាងពីវិវាទសម្ថកិច្ចនៅក្នុងការបំពេញនូវតួនាទី ភារៈកិច្ច និងអំណាចដែលច្បាប់បានផ្តល់ឱ្យ រាល់ព្រះរាជអាជ្ញាគ្រប់រូបត្រូវតែបំពេញនូវការងាររបស់ខ្លួននៅក្នុងដែនសម្ថកិច្ចមួយដែលច្បាប់បានកំណត់។

### ក. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

សមត្ថកិច្ចរបស់ព្រះរាជអាជ្ញាត្រូវបានបែងចែកតាមដែនដី។ ព្រះរាជអាជ្ញាដែលមានសម្ថកិច្ចគឺ៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនរបស់ជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស [៦]។

[៦] មាត្រា៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ព្រះរាជអាជ្ញាអាចមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត ស្រាវជ្រាវលើរឿងក្តីព្រហ្មទណ្ឌណាមួយដែលបានកើតឡើងបានគឺត្រូវមើលទៅលើលក្ខខណ្ឌទីតាំងនៃបទល្មើសនោះ។ នៅពេលដែលមានបទល្មើសមួយកើតមានឡើងការស្រាវជ្រាវ និងត្រូវបានធ្វើឡើងជាច្រើនកន្លែង ដែលជាទីតាំងដែលពាក់ព័ន្ធដល់ការប្រព្រឹត្តនូវបទល្មើសនោះឡើងរួមមាន ទីកន្លែងប្រព្រឹត្តបទល្មើស ទីលំនៅរបស់ជនសង្ស័យ និងទីកន្លែងដែលចាប់ខ្លួនរបស់ជនសង្ស័យ។ ដូច្នេះសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាគ្រប់រូបគឺ ត្រូវអនុវត្តតាមគោលការណ៍ដែនដីដែលពាក់ព័ន្ធទៅនឹងទីតាំងបទល្មើសផ្ទាល់។

## ខ. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាជាតួអង្គមួយយ៉ាងសំខាន់នៅក្នុងអង្គការអយ្យការ ដោយសារព្រះរាជអាជ្ញាគឺជាអ្នកតំណាងឱ្យអង្គការអយ្យការដែលអមនឹងសាលាជម្រះក្តី និងជាបុគ្គលដែលមានមានតួនាទីយ៉ាងសកម្មក្នុងចំណាត់ការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ។ ចំណាត់ការទៅលើរឿងក្តីរបស់ព្រះរាជអាជ្ញាមានដូចជាស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ការពិនិត្យមើលទៅលើនីត្យានុកូលភាពនៃការស៊ើបអង្កេត ការពិនិត្យមើលទៅលើសេចក្តីសម្រេចរបស់តុលាការ និងបំពេញនៅតួនាទីផ្សេងៗទៀតក្នុងនាមជាអ្នកតំណាងឱ្យផលប្រយោជន៍សាធារណៈ។ នៅរាល់ចំណាត់ការរបស់ព្រះរាជអាជ្ញាទៅលើរឿងក្តីព្រហ្មទណ្ឌត្រូវតែជាចំណាត់ការដែលច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តនៅក្នុងស្រុក។

ព្រះរាជអាជ្ញាទាំងអស់ត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវ ម៉ឺងម៉ាត់ ឆាប់រហ័ស និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ហើយត្រូវតែគោរព និងការពារនូវសេចក្តីថ្លៃថ្នូរបស់មនុស្ស ដោយការលើកកម្ពស់នូវសិទ្ធិមនុស្ស។ ហេតុដូច្នេះត្រូវរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងមានភាពរលូន។

ព្រះរាជអាជ្ញាមិនត្រូវផ្តើមគំនិតចោទប្រកាន់ ឬបន្តចោទប្រកាន់ ឬក៏មិនត្រូវខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីតំកល់រឿងមិនចាត់ការ និងបើកដំណើរការស៊ើបអង្កេតមួយដែលមានលក្ខណៈលំអៀងនោះទេ ព្រោះការធ្វើបែបនេះបង្ហាញឱ្យឃើញថា ជាការចោទប្រកាន់នេះពុំមានមូលដ្ឋានត្រឹមត្រូវ ។

ព្រះរាជអាជ្ញា ត្រូវផ្តល់ការយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញាចំពោះមន្ត្រីសាធារណៈ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសពីអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋដទៃៗទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយ និងការស៊ើបអង្កេតអំពីបទល្មើសទាំងនេះ នៅទីណាដែលមានការអនុញ្ញាត្តិដោយច្បាប់ ឬស្របទៅនឹងការអនុវត្តតាមតំបន់ ។

នៅពេលណាដែលព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនជាប់សង្ស័យដែលគេដឹង ឬមានជំនឿលើមូលដ្ឋានសមហេតុផលថា ភស្តុតាងទាំងនោះបានមកដោយប្រើប្រាស់វិធីមិនស្របច្បាប់ ដែល

អាចចាត់ទុកបានថាជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬការប្រព្រឹត្តសកម្មភាពកាចសាហាវ អមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភសិទ្ធិមនុស្សផ្សេងៗទៀត។ ព្រះរាជអាជ្ញាត្រូវបដិសេធ មិនប្រើភស្តុតាងបែបនោះប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬត្រូវជម្រាបដល់តុលាការតាមនោះ ហើយត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថា អ្នកដែលទទួលខុសត្រូវចំពោះការប្រើវិធីបែបនោះ ត្រូវបាននាំខ្លួនមកកាន់តុលាការ7។

## គ. ភារកិច្ចរបស់ព្រះរាជអាជ្ញា

ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាពក្នុងការបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវឈរលើគោលការណ៍សំខាន់ៗមួយចំនួនក្នុងការអនុវត្តនៅកាតព្វកិច្ចរបស់ខ្លួន ដែលគោលការណ៍ទាំងនោះរួមមាន[៧]៖

- អនុវត្តមុខងារ និងតួនាទីរបស់ខ្លួនដោយមិនលំអៀង ជៀសវាងពីការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ សាសនា ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត។
- ការពារផលប្រយោជន៍ជូនសាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬគ្មានប្រយោជន៍ដល់ជនសង្ស័យក៏ដោយ។
- ត្រូវរក្សារឿងក្ដីជាសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬពុំដូច្នោះទេគឺជាតម្រូវការរបស់តុលាការក្នុងការបញ្ជាក់ពីភាពយុត្តិធម៌។
- ពិនិត្យមើលទិដ្ឋភាពទូទៅ និងក្ដីបារម្ភជនរងគ្រោះនៅពេលដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ជនរងគ្រោះ ដើម្បីឱ្យស្របតាមសេចក្ដីប្រកាសស្ដីពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានរបស់ជនរងគ្រោះក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច។

## ឃ. អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិ និងអំណាចរបស់ខ្លួនស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តិនានាដែលនៅជាធរមាន។ នីតិវិធីព្រហ្មទណ្ឌបានផ្ដល់អំណាចជូនដល់ព្រះរាជអាជ្ញានៅក្នុងដំណាក់កាលនៃការចោទប្រកាន់

[៧] គោលការណ៍ណែនាំស្ដីពី "តួនាទីរបស់ព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ សីហា ដល់ថ្ងៃទី៧ កញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងការ៉ាណា

ដែលជាតំណាក់កាលមួយដែលព្រះរាជអាជ្ញាជាអ្នកមានសមត្ថកិច្ច និងទទួលបន្ទុកលើការផ្តល់ចំណាត់ការក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ។ ចំពោះអំណាចរបស់ព្រះរាជអាជ្ញាក្នុងដំណាក់កាលនៃការចោទប្រកាន់នេះ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ជូននូវអំណាចចំនួន៣ដល់ព្រះរាជអាជ្ញា អំណាចទាំងនោះរួមមាន៖ អំណាចលើនគរបាលយុត្តិធម៌ អំណាចក្នុងការស៊ើបអង្កេត និងអំណាចក្នុងការចោទប្រកាន់។

- **អំណាចលើមន្ត្រីនគរបាលយុត្តិធម៌៖** យោងតាមមាត្រា៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងអំពីអំណាចរបស់ព្រះរាជអាជ្ញាទៅលើមន្ត្រីនគរបាលយុត្តិធម៌ថា "ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងាររបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសម្តកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែកាលណាអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់ខ្លួន។ នៅក្នុងករណីចាំបាច់ ព្រះរាជអាជ្ញា អាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំដាក់សមាសភាព មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ថ្មី ដើម្បីធ្វើការស៊ើបអង្កេតជំនួស។ ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចទៅអង្គភាពនគរបាលយុត្តិធម៌បានគ្រប់ពេលវេលា ដើម្បីពិនិត្យការអនុវត្តការងារលើសំណុំរឿង។
- **អំណាចក្នុងការស៊ើបអង្កេត៖** មុននឹងសម្រេចធ្វើការចោទប្រកាន់ចំពោះអំពើណាមួយព្រះរាជអាជ្ញាត្រូវធ្វើការស៊ើបអង្កេតជាមុន ក្នុងការស្វែងរកភស្តុតាង និងធាតុផ្សំបទល្មើសឲ្យបានគ្រប់គ្រាន់។ ក្នុងការស៊ើបអង្កេត ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់ក្នុងការស៊ើបអង្កេត។ ដូច្នេះ ព្រះរាជអាជ្ញាអាចប្រើប្រាស់អំណាចទាំងអស់ក្នុងការស៊ើបអង្កេត ទោះបីជាការស៊ើបអង្កេតបឋមក្តី ការស៊ើបអង្កេតករណីជាក់ស្តែងក្តីដែលអំណាចទាំងនោះមានដូចជា៖ ការឆែកឆេរ ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយការបញ្ជាឲ្យចូលខ្លួន ការធ្វើកោសល្យវិច័យ ការឃាត់ខ្លួន[៩] ។ល។
- **អំណាចក្នុងការចោទប្រកាន់៖** ការចោទប្រកាន់ គឺជាអំណាចចំបង និងសំខាន់បំផុតដែលព្រះរាជអាជ្ញា ប្រើប្រាស់ដើម្បីឲ្យសំណុំរឿងព្រហ្មទណ្ឌមួយអាចដំណើរការទៅដំណាក់កាលបន្ទាប់បាន។ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ អំណាចក្នុងការចោទប្រកាន់បានផ្តល់ឲ្យព្រះរាជអាជ្ញាក្នុងការជ្រើសរើសវិធីក្នុងការចោទប្រកាន់ ឬសម្រេចមិនធ្វើការចោទប្រកាន់ ដោយត្រូវបានហៅថា

**"ជម្រើសនៃការចោទប្រកាន់"** ឬ **"គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់"** ដែលនឹងត្រូវបកស្រាយក្នុងជំពូកបន្ទាប់។

# ជំពូកទី២

# ការចោទប្រកាន់របស់ព្រះរាជអាជ្ញា

នៅក្នុងដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ច្បាប់បានប្រគល់អំណាចដល់អង្គការអយ្យការជាអ្នកធ្វើការចោទប្រកាន់។ មានតែស្ថាប័នអយ្យការទេដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញា[9]។ ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា និងជាអ្នកធ្វើការចោទប្រកាន់ទៅលើជនដែលបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ។ បណ្តឹងអាជ្ញាត្រូវបានអនុវត្តទៅលើបុគ្គលគ្រប់រូបទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ[10]។ ចំពោះការចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវបានដំណើការឡើង នៅក្រោយពេលដែលព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹងពីសំណាក់ជនរងគ្រោះក្នុងរឿងក្តីព្រហ្មទណ្ឌផ្ទាល់ ឬតាមរយៈពាក្យបណ្តឹងដែលបញ្ជូនមកតាមរយៈមន្ត្រីនគរបាលយុត្តិធម៌។ ជាគោលការណ៍ព្រះរាជអាជ្ញាមិនអាចបដិសេធមិនធ្វើការចោទប្រកាន់នៅក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌណាមួយនោះទេ ក្នុងករណីដែលសំណុំរឿងនោះបានពិនិត្យមើលទៅឃើញថាមាននូវអត្ថិភាពនៃបទល្មើស ជនល្មើសមាននូវពិរុទ្ធភាព និងមានស្ថានភាពចាំបាច់ក្នុងការធ្វើការចោទប្រកាន់។ ការដែលព្រះរាជអាជ្ញាមិនអាចបដិសេដមិនធ្វើការចោទប្រកាន់ក្នុងសំណុំរឿងព្រហ្មទណ្ឌក្នុងករណីដូចខាងលើគឺដើម្បីគោរពនូវគោលការណ៍របស់ស្ថាប័នអយ្យការក្នុងការបំពេញនៅតួនាទីរបស់ខ្លួនដែលជាម្ចាស់នៃបណ្តឹងអាជ្ញា និងជាអ្នកការពារផលប្រយោជន៍ សណ្តាប់ធ្នាប់សារណៈជូនដល់សង្គម។

អ្វីទៅជាការចោទប្រកាន់របស់ព្រះរាជអាជ្ញា? ការចោទប្រកាន់របស់ព្រះរាជអាជ្ញាគឺជាចំណាត់ការមួយក្នុងនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ។ ចំណាត់ការនៃការចោទប្រកាន់នេះ មានអនុភាពក្នុងការផ្ទេរសម្តកិច្ចពីអយ្យការ ទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ឬអាចនិយាយម្យ៉ាងទៀតបានថា ជាចំណាត់ការក្នុងការបញ្ជូនជនល្មើសមួយ ឬច្រើននាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ ឬទៅចំពោះមុខចៅក្រមជំនុំជម្រះដើម្បីធ្វើការផ្តន្ទាទោសលើជនល្មើសនោះឱ្យស្របទៅតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រោយពីទទួលបាននូវពាក្យបណ្តឹងព្រហ្មទណ្ឌ និងការស្រាវជ្រាវរកពត៌មាន និងភស្តុតាងដែលអាចកំណត់បានថាសំនុំរឿងដែលបានធ្វើការដាក់ពាក្យបណ្តឹងមកនោះ ព្រះរាជអាជ្ញាអាចសម្រេចធ្វើចំណាត់ការលើការចោទប្រកាន់តាមរយៈនីតិវិធីជាក់ស្តែងចំនួនបី[11]៖

[9] មាត្រា១៣១ ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[10] មាត្រា ៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[11] មាត្រា៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ផ្នែកទី១ ការបើកការស៊ើបសួរ**

**ផ្នែកទី២ ការបញ្ជូនរឿងទៅជម្រះផ្ទាល់**

**ផ្នែកទី៣ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម**

## ផ្នែកទី១៖ ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរសំដៅដល់ការផ្ដើមនីតិវិធីក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ក្រោយពីទទួលការប្ដឹងរបស់ព្រះរាជអាជ្ញា ឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមាននៅក្នុង **ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ**។ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ12។ ការបើកការស៊ើបលើអង្គហេតុរបស់ចៅក្រមស៊ើបសួរមានលក្ខណៈខុសពីការស៊ើបអង្កេតស្រាវជ្រាវរករបស់ព្រះរាជអាជ្ញា ព្រោះការស្រាវជ្រាវរបស់ព្រះរាជអាជ្ញាជាការស្រាវជ្រាវ និងស៊ើបអង្កេតរកនូវពត៌មាន និងភស្តុតាងទាំងឡាយណាដែលបញ្ជាក់ពីអត្ថិភាពនៃបទល្មើសដើម្បីធ្វើការចោទប្រកាន់។ ប៉ុន្តែនៅក្នុងការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរវិញ ចៅក្រមស៊ើបសួរត្រូវតែបំពេញនូវកិច្ចការស្រាវជ្រាវ ដើម្បីស្វែងរកឱ្យឃើញការពិតនូវអត្ថិភាព ឬនត្ថិភាពនៃបទល្មើសដែលព្រះរាជអាជ្ញាមានធ្វើការចោទប្រកាន់តាមរយៈសំណុំរឿង និងធ្វើការស្រាវជ្រាវលើគ្រប់ទិន្នន័យ និងពត៌មាន ក៏ដូចជាភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដែលមាននៅក្នុងសំណុំរឿងផងដែរ។ តាមមាត្រា១២៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងថាការស៊ើបសួរអាចបើកប្រឆាំងនិងបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនិងអញ្ញាតជនដោយអនុលោមតាមវាក្យខណ្ឌទី២ នៃមាត្រា៤៤ (ការបើកការស៊ើបសួរ)។ ការបើកការស៊ើបសួរតាមរយៈការចោទប្រកាន់របស់ព្រះរាជអាជ្ញានេះត្រូវទាមទារឱ្យមាននូវការគោរពលក្ខខណ្ឌអនុគ្រោះមួយចំនួន ហើយត្រូវស្របតាមនីតិវិធីជាក់លាក់ និងស្របតាមទម្រង់ការនៃដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាដាច់ខាត និងដើម្បីបង្កើតឱ្យមានអានុភាពផ្សេងៗទៀត។

### ក. លក្ខខណ្ឌដែលនាំឱ្យមានការបើកការស៊ើបសួរ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់បង្ហាញអំពីលក្ខខណ្ឌមួយចំនួនដែលនាំរឿងក្ដីព្រហ្មទណ្ឌមួយឈានដល់ការបើកការស៊ើបសួរ ដោយស្របតាមនីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ តាមរយៈក្រមនីតិវិធីលក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរគឺសំដៅដល់លក្ខខណ្ឌប្រភេទនៃបទល្មើស ដោយត្រូវកំណត់មើលអំពីប្រភេទនៃបទល្មើសជាមុនសិនទើបព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់តាមរយៈនីតិវិធីនៃការបើកការស៊ើបសួរបាន។

[១២] មាត្រា១២៤ កថាខណ្ឌទី៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប្រភេទនៃបទល្មើសដែលជាលក្ខខណ្ឌដែលតម្រូវឲ្យធ្វើការបើកការស៊ើបសួរមានចំនួនពីរគឺ បទឧក្រិដ្ឋ និងបទមជ្ឈឹម។13

**ការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋៈ** តាមមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានចែងថាៈ "នៅក្នុងករណីបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ"។ ច្បាប់បានបញ្ញត្តិអំពីភាពដាច់ខាតក្នុងការបើកការស៊ើបសួរចំពោះករណីបទឧក្រិដ្ឋគឺដោយហេតុថាបទឧក្រិដ្ឋ ជាប្រភេទបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ និងមានអតិប្បរមានៃទោសដាក់ពន្ធនាគារចាប់ពីប្រាំឆ្នាំ រហូតទៅដល់សាមសិបឆ្នាំ ឬអស់មួយជីវិត។ មានន័យថា កម្រិតនៃទោសរបស់បទល្មើសប្រភេទនេះគឺមានលក្ខណៈធ្ងន់ធ្ងរ ដូច្នេះទើបតម្រូវឲ្យមានការបើកការស៊ើបសួរទាមទារឲ្យមាននូវការស្រាវជ្រាវ នឹងពិនិត្យយ៉ាងហ្មត់ចត់ជាមុនសិន ទើបអាចសម្រេចបញ្ជូនជនល្មើសទៅធ្វើការជំនុំជម្រះនៅមុខតុលាការបាន ដើម្បីប្រាកដថាគ្មានការចោទប្រកាន់ដោយសារការភាន់ច្រលំ ដែលជាហេតុធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនដែលត្រូវបានចោទប្រកាន់ និងដើម្បីធានាឲ្យបាននូវភាពយុត្តិធម៌ក្នុងដំណើរការកាត់ក្តីរបស់តុលាការ។ ចៅក្រមស៊ើបសួរអាចបើកការស៊ើបសួរចំពោះករណីបទឧក្រឹដ្ឋបាន តាមរយៈដីការសម្រេចបញ្ជូនរឿងឲ្យស៊ើបសួរដែលចេញដោយតំណាងអយ្យការ ។ ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរត្រូវធ្វើឡើងដោយស្រាវជ្រាវយ៉ាងល្អិតល្អន់ចំពោះសំណុំរឿងនោះពោលគឺត្រូវតែស្រាវជ្រាវទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុកដើម្បីស្វែងរក និងលាតត្រដាងនូវការពិតឲ្យកាន់តែច្បាស់មួយកម្រិតបន្ថែមទៀតក្រៅពីការជំនុំជម្រះរបស់យុត្តាធិការជំនុំជម្រះ។

**ការបើកការស៊ើបសួរចំពោះបទមជ្ឈឹមៈ** បទមជ្ឈឹមជាប្រភេទបទល្មើសដែលមានចំនួនអតិប្បរមានៃទោសដាក់ពន្ធនាគារចាប់ពី០៦ ថ្ងៃ ដល់ ០៥ឆ្នាំ14។ យោងតាមមាត្រា៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានកំណត់ថាព្រះរាជអាជ្ញាអាចប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ ឬនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ចំពោះប្រភេទបទល្មើសបទមជ្ឈឹមនេះ ហើយព្រះរាជអាជ្ញាក៏អាចប្រើនីតិវិធីក្នុងការបើកការស៊ើបសួរបានដែរ។ មានន័យថាចំពោះបទល្មើសមជ្ឈឹមគឺគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការសម្រេចអំពីចំណាត់ការនៃការចោទប្រកាន់របស់ខ្លួនថាត្រូវប្រើតាមនីតិវិធីមួយណា ក្នុងចំណោមនីតិវិធីទាំង០៣ ដោយព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងអំពីស្ថានភាពនៃបទល្មើស ប្រសិនបើជនដែលត្រូវចោទបានប្រព្រឹត្តនូវបទមជ្ឈឹម ប៉ុន្តែការចោទប្រកាន់នោះមិនមាននូវភ័ស្តុតាងគ្រប់គ្រាន់ ឬជនល្មើសជាអញ្ញាត្តជនពុំមានអត្តសញ្ញាណច្បាស់លាស់ ដែលជា

[13] មាត្រា១១២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[14] មាត្រា៤៦ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ហេតុមិនអាចបង្គាប់ឲ្យជនសង្ស័យចូលបង្ហាញខ្លួនភ្លាមបាន និងការដែលសំណុំរឿងមិនទាន់មូល ធ្វើឲ្យមិនអាចបញ្ជូនរឿងនោះទៅជំនុំជម្រះដោយផ្ទាល់បាន។

### ខ. នីតិវិធីនៃការបើកការស៊ើបសួរ

តាមមាត្រា៤០ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនមក។ ក្នុងមាត្រានេះបានកំណត់បង្ហាញថានៅក្នុងរឿងក្តីព្រហ្មទណ្ឌ មុននិងព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តក្នុងការចោទប្រកាន់ដោយនីតិវិធីបើកការស៊ើបសួរ ឬនីតិវិធីផ្សេងៗទៀត ព្រះរាជអាជ្ញាត្រូវធ្វើការវាយតម្លៃទៅលើសំណុំរឿងដែលមានប្រភពមកពីពាក្យបណ្តឹងដែលព្រះរាជអាជ្ញាបានទទួលដោយផ្ទាល់តាមរយៈដើមបណ្តឹង ឬតាមរយៈការបញ្ជូនសំណុំរឿងមកពីមន្ត្រីនគរបាលយុត្តិធម៌។

#### ១. ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងដែលបញ្ជូនមកដោយផ្ទាល់

ដើមបណ្តឹងអាចដាក់ពាក្យបណ្តឹងមកកាន់ព្រះរាជអាជ្ញាដោយផ្ទាល់បាន ដើម្បីសុំឲ្យព្រះរាជអាជ្ញាធ្វើចំណាត់ការទៅលើពាក្យបណ្តឹងនោះ។ នៅក្រោយពេលដែលព្រះរាជអាជ្ញាបានទទួលពាក្យបណ្តឹងពីសំណាក់ដើមបណ្តឹង ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងសម្រេចធ្វើចំណាត់ការក្នុងការចោទប្រកាន់តាមរយៈនីតិវិធីណាមួយ ប្រសិនបើអង្គហេតុនៅក្នុងពាក្យសំណុំរឿងនោះពិនិត្យទៅឃើញថាជាបទល្មើស។ នីតិវិធីក្នុងការថ្លឹងថ្លែង និងស្រាវជ្រាវត្រូវធ្វើឡើងតាមរយៈការសុំឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើការបើកការស៊ើបអង្កេតបឋម ឬកោះហៅដើមបណ្តឹង ឬសាក្សីមកសួរ និងស្តាប់ចម្លើយដោយផ្ទាល់។ បន្ទាប់ពីការស៊ើបអង្កេត និងស្រាវជ្រាវបានបញ្ចប់ ហើយនបានរកឃើញថាអង្គហេតុនោះជាបទល្មើស ហើយបានបំពេញនៅលក្ខខណ្ឌដែលនាំឲ្យមានបើកការស៊ើបសួរបាន ព្រះរាជអាជ្ញា និងសម្រេចចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរទៅសំណាក់ចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿឲ្យស៊ើបសួរ។

#### ២. ការបើកការស៊ើបសួរតាមរយៈសំណុំរឿងបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ទទួលបានពាក្យបណ្តឹងបរិហារ និងពាក្យបណ្តឹងទាមទារក្នុងដែនសមត្ថកិច្ចរបស់ខ្លួនហើយ មន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតបឋមលើពាក្យបណ្តឹងដែលខ្លួនទទួលបាន ឬនៅពេលដឹងអំពីបទល្មើសនោះថាជាបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុណាមួយ រួចកសាងសំណុំរឿងបញ្ជូនទៅតំណាងអយ្យការ។ ចំពោះករណីបទល្មើសជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើចាប់ខ្លួន និងឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅចំពោះមុខព្រះរាជអាជ្ញា។ ដូចនេះ នីតិវិធីក្នុងការធ្វើចំណាត់ការលើសំណុំរឿងដែលបញ្ជូនមកតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងតាមករណីដូចខាងក្រោម៖

- **ករណីសំណុំរឿងគ្មានជនសង្ស័យ (ក្រៅឃុំ)៖** នៅក្នុងករណីដែលសំណុំរឿងគ្មានជនសង្ស័យ ដែលជនសង្ស័យមមិនត្រូវបានបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយសារជនសង្ស័យពុំត្រូវបានបញ្ជូនទៅកាន់ព្រះរាជអាជ្ញានោះទេ។ នៅពេលដែលព្រះរាជអាជ្ញាទទួលបានសំណុំរឿងព្រះរាជអាជ្ញា និងធ្វើការថ្លឹងថ្លែងអង្គហេតុដោយពិនិត្យមើលភស្តុតាងដែលមានក្នុងសំណុំរឿង របាយការសំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ និងកោះហៅដើមបណ្តឹង ជនសង្ស័យ សាក្សី ដើម្បីសួរ និងស្តាប់ចម្លើយ។ បន្ទាប់មកនៅពេលដែលពិនិត្យទៅឃើញថាអង្គហេតុខាងលើគឺជាបទល្មើស និងបានបំពេញលក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវធ្វើចំណាត់ការចោទប្រកាន់ដោយនីតិវិធីបើកការស៊ើបសួរ និងចេញដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។
- **ករណីសំណុំរឿងមានខ្លួនជនសង្ស័យ (ក្នុងឃុំ)៖** ក្នុងករណីដែលសំណុំរឿង ដែលជនសង្ស័យត្រូវបានចាប់ខ្លួន និងបញ្ជូនខ្លួនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវបាននាំមកបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា បន្ទាប់ពីផុតពីរយៈពេលនៃការឃាត់ខ្លួនណ្តោះអាសន្ន។ វត្ថុតាង(បើមាន) និងជនសង្ស័យនៅក្នុងសំណុំរឿងដែលបានបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបញ្ជូនមកដល់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញា និងធ្វើការសួរចម្លើយ និងពិនិត្យទៅលើសំណុំរឿងនោះ។ បន្ទាប់មកនៅពេលដែលពិនិត្យទៅឃើញថាអង្គហេតុខាងលើគឺជាបទល្មើស និងបានបំពេញលក្ខខណ្ឌដែលនាំឲ្យមានការបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវធ្វើចំណាត់ការចោទប្រកាន់ដោយនីតិវិធីបើកការស៊ើបសួរ និងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

## គ. ទម្រង់ចាំបាច់ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

នៅក្នុងនីតិវិធីនៃការបើកការស៊ើបសួរជាចាំបាច់ត្រូវមានដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវធ្វើឡើងតាមទម្រង់ដែលជាក់លាក់មួយ ដើម្បីធានាឲ្យបានពីអានុភាពស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធី។ ទម្រង់របស់ដីការសន្និដ្ឋានបញ្ជូនឲ្យស៊ើបរឿងដូចតទៅ៖

- **សេចក្តីសង្ខេបអង្គហេតុ**
- **ការកំណត់ឈ្មោះបទល្មើស**
- **ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស**
- **ឈ្មោះបុគ្គលដែលត្រូវស៊ើបសួរប្រសិនបើអាចកំណត់បាន។**

## ឃ. អានុភាពនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ

បន្ទាប់ពីព្រះរាជអាជ្ញា សម្រេចចោទប្រកាន់តាមរយៈដីការសន្និដ្ឋានឲ្យស៊ើបសួរ វានាំឲ្យដីការនេះបង្កើតឲ្យមានអានុភាពមួយចំនួនដូចជា ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឲ្យបើកកិច្ចស៊ើបសួរ និងការកំណត់ព្រំដែនសមត្ថកិច្ចស៊ើបសួរ។

- ការផ្តាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស៖ ថេរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមពីពេលប្រព្រឹត្តិបទល្មើស។ អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ។ មានន័យថា គ្រប់កិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញា មិនថាតាមរយៈការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ការបង្ហាញខ្លួនភ្លាម ឬការបើកការស៊ើបសួរនោះទេ វាជាសញ្ញាណនៃការចោទប្រកាន់មួយដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស។ រីឯគ្រប់កិច្ចនៃការស៊ើបសួរ សំដៅទៅដល់កិច្ចដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលកិច្ចនោះក៏មានអានុភាពផ្តាច់អាជ្ញាយុកាលនៃ បណ្តឹងអាជ្ញាយុកាលផងដែរ។
- ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឲ្យបើកការស៊ើបសួរ៖ គ្មានការស៊ើបសួរណាមួយ អាចបើកបានដោយគ្មានកិច្ចចោទប្រកាន់របស់ព្រះរាជអាជ្ញាទេ លើកលែងការដាក់ឲ្យមានចលនានៃបណ្តឹងអាជ្ញាដោយជនរងគ្រោះ។ កិច្ចស៊ើបសួរដែលបើកដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នោះកិច្ចស៊ើបសួរត្រូវចាត់ទុកជាមោឃៈ។ ការប្តឹងមោឃភាពគឺ ត្រូវប្តឹងទៅសភាស៊ើបសួរគ្រប់ពេលវេលានៅពេលដែលមានការរកឃើញថាការស៊ើបសួរណាមួយខុសពីនីតិវិធី។ នៅពេលដែលចេញដីកាដំណោះស្រាយគឺ មានអានុភាពលុបលាងមោឃភាពនៃនីតិវិធីមុន មានន័យថាទោះបីជាកិច្ចស៊ើបសួរណាមួយដែលអាចជាកម្មវត្ថុនៃមោឃភាពក៏ដោយ ក៏មិនអាចលើកមកពិចារណាម្តងទៀតនៅពេលជំនុំជម្រះបានដែរ។
- កំណត់អំពីព្រំដែនសមត្ថកិច្ចលើការស៊ើបសួរ៖ ការបើកការស៊ើបសួរគឺជាសម្តកិច្ចរបស់ចៅក្រមស៊ើបសួរ ក៏ប៉ុន្តែចៅក្រមស៊ើបសួរអាចមានសម្តកិច្ចក្នុងការបើកការស៊ើបសួរបានលុះត្រាតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលសម្រេច នឹងចេញដោយតំណាងអយ្យការ។ ក្នុងករណីដែលមានលេចឡើងនូវអង្គហេតុថ្មីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌមួយ ដែលកំពុងត្រូវបានធ្វើការស៊ើបសួរ ចៅក្រមស៊ើបត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនោះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹងទៅចៅក្រមស៊ើបសួរឲ្យធ្វើការស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មីនោះបានតាមរយៈការចេញដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែ

ម។115 រាល់ការបើកការស៊ើបសួរបន្ថែមក៏ដូចជាការបើកការស៊ើបសួរដែលប្រសិនបើការបើកការស៊ើបសួរបន្ថែមនោះ ធ្វើឡើងដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីសំណាក់ព្រះរាជអាជ្ញានោះទេ ការស៊ើបសួរបន្ថែមនោះ នឹងក្លាយទៅជាមោឃៈ លើកលែងតែនៅក្នុងករណីដែលអង្គហេតុថ្មីនោះពិនិត្យទៅឃើញថាជាបទល្មើសដដែល ប៉ុន្តែមាននូវស្ថានទម្ងន់ទោស។

## ផ្នែកទី២៖ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីដែលព្រះរាជអាជ្ញាបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង ដើម្បីធ្វើការជំនុំជម្រះដោយផ្ទាល់តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។16 ការទទួលយកការបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានគោលបំណងធានាសិទ្ធិរបស់ជនល្មើស ក្នុងការទទួលបាននូវការជំនុំជម្រះរបស់តុលាការដោយទាមទារឲ្យមានការធ្វើការចោទប្រកាន់ជនល្មើស និងបញ្ជូនអង្គហេតុទៅយុត្តាធិការជំនុំជម្រះតែម្តង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីណាផ្សេងទៀតឡើយ។ មិនត្រឹមតែប៉ុណ្ណោះដំណើរការនៃនីតិវិធីនេះ គឺវាមានលក្ខណៈឆាប់រហ័ស ពីព្រោះការចោទប្រកាន់ត្រូវបានផ្ទេរពីសមត្ថកិច្ចរបស់អង្គការអយ្យការទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះតែម្តង។ យ៉ាងណាមិញដើម្បីឲ្យនីតិវិធីនេះអាចប្រព្រឹត្តទៅបាន គឺទាមទារឲ្យមានការគោរពលក្ខខណ្ឌមួយចំនួន ហើយត្រូវអនុវត្តឲ្យស្របតាមនីតិវិធីមួយជាក់លាក់ ដែលនីតិវិធីនេះត្រូវតែធ្វើឡើងតាមទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដើម្បីឈានឲ្យមានអានុភាពទៅដល់ចំណាត់ការយុត្តាធិការជំនុំជម្រះផងដែរ។

### ក. លក្ខខណ្ឌដែលនាំឲ្យមានការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

មុននឹងឈានទៅដល់ការសម្រេចចោទប្រកាន់តាមនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ចាំបាច់ទាមទារឲ្យព្រះរាជអាជ្ញាគោរពនូវលក្ខខណ្ឌមួយចំនួន។ លក្ខខណ្ឌទាំងនោះ គឺសំដៅទៅដល់លក្ខខណ្ឌនៃបទល្មើស និងលក្ខខណ្ឌនៃសាវតាជាតិរបស់ជនល្មើសដែលចាំបាច់ត្រូវបំពេញ។

#### ១. លក្ខខណ្ឌនៃបទល្មើស

នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ អាចធ្វើឡើងបានចំពោះ បទមជ្ឈិម និងបទលហុតែប៉ុណ្ណោះ។

ចំពោះបទមជ្ឈិម៖ ថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ពុំបានចែងច្បាស់ថាជាប្រភេទបទមជ្ឈិមបែបណាដែលអាចអនុញ្ញាតឲ្យព្រះរាជអាជ្ញាអនុវត្តនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏ដោយ ក៏ប៉ុន្តែគេបានផ្តល់ឆន្ទានុសិទ្ធិ

---

[១៥] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[១៦] មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងពីស្ថានភាពនៃបទល្មើស។ដោយឡែកបើព្រះរាជអាជ្ញា មើលឃើញថា បទមជ្ឈិមនោះមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឲ្យតុលាការធ្វើការជំនុំជម្រះវិនិច្ឆ័យសេចក្តីលើរឿងនេះបាន ព្រះរាជអាជ្ញានឹងប្រើនីតិវិធីនៃការចោទប្រកាន់នេះ។ ផ្ទុយមកវិញបទមជ្ឈិមអាចជាកម្មវត្ថុនៃការចោទប្រកាន់តាមទម្រង់ជាការបើកការស៊ើបសួរ និងជាការបង្ហាញខ្លួនភ្លាមផងដែរ ព្រោះមានស្ថានភាពនៃបទមជ្ឈិមមួយចំនួនត្រូវបានទទួលឲ្យមានការចោទប្រកាន់តាមនីតិវិធីផ្សេងទៀតបាន។ ដូចជាស្ថានភាពនៃបទមជ្ឈិមដែលមានលក្ខណៈស្មុគស្មាញ ទាមទារឲ្យមានការបើកការស៊ើបអង្កេតស្វែងរកភស្តុតាងគ្រប់គ្រាន់ ឬបទល្មើសដែលមិនស្គាល់អត្តសញ្ញាណជនល្មើសជាដើម។

ចំពោះបទលហុះ ព្រះរាជអាជ្ញាត្រូវតែជ្រើសរើសយកវិធីនៃការចោទប្រកាន់នេះ។ មិនមានបទប្បញ្ញត្តិណាផ្សេងដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាបើកការស៊ើបសួរ ឬប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះបទលហុនោះទេ។ មូលហេតុ គឺដោយសារតែបទលហុជាបទល្មើសតូចតាច ដោយមានអតិបរិមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើ៦ថ្ងៃ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ ឬត្រឹមតែជាបទល្មើសដែលត្រូវផ្តន្ទាទោសដែលគ្រាន់តែពិន័យជាប្រាក់ប៉ុណ្ណោះ។ ដោយមើលឃើញថាបទលហុជាប្រភេទបទល្មើសដែលត្រូវផ្តន្ទាទោសស្រាល ដូចនេះគ្មានជម្រើសផ្សេងដែលល្អជាង ការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នោះទេ ពីព្រោះវាអាចការពារមិនឲ្យមានការប៉ះពាល់សិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងររបស់ជនជាប់ចោទ និងផ្តល់ផលប្រយោជន៍ដល់តុលាការក្នុងការធ្វើដំណើរការរឿងក្តីបានឆាប់រហ័សផងដែរ។ គួរបញ្ជាក់ផងដែរថា ទោះបីជាការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ចំពោះករណីបទលហុ ឬបទមជ្ឈិមក៏ដោយ ការបញ្ជូនទៅជំនុំជម្រះនេះត្រូវតែធ្វើឡើងតាមរយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់។

### ២. លក្ខខណ្ឌសាវតាជាតិរបស់ជនល្មើស

ក្រៅពីការកំណត់ឲ្យបានអំពីប្រភេទនៃបទល្មើសហើយ ព្រះរាជអាជ្ញាចាំបាច់ត្រូវរកឲ្យឃើញអំពីសាវតាជាតិរបស់ជនល្មើស នេះក៏ជាលក្ខខណ្ឌចាំបាច់មួយដែរ ព្រោះជាស្មារតីក្នុងការធ្វើបណ្តឹងអាជ្ញា គឺមានគោលបំណងមិនត្រឹមតែស្វែងរកអត្ថិភាពនៃបទល្មើសទេ អ្វីដែលសំខាន់នោះ គឺចង់ឲ្យមានការផ្តន្ទាទោសចំពោះជនល្មើសទៀតផង។ ការចោទប្រកាន់តាមទម្រង់ជាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែលមិនស្គាល់ជនល្មើស មិនអាចប្រព្រឹត្តទៅបាន។ ម្យ៉ាងទៀត ក្រមនីតិវិធីទទួលស្គាល់វិសាលភាពនៃបណ្តឹងចំពោះជនជាប់ចោទ គឺមានន័យថាតុលាការនឹងជំនុំជម្រះតែជនណាដែលមានក្នុងពាក្យដែលប្តឹងមកខ្លួនប៉ុណ្ណោះ។ ដូចនេះការស្គាល់អត្តសញ្ញាណរបស់ជនល្មើសជាលក្ខខណ្ឌត្រូវតែមានដែលខ្វះមិនបាន។

## ខ. នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជានីតិវិធីមួយដែលមិនឆ្លងកាត់ដំណាក់កាលនៃការស៊ើបសួរទេ ពោលគឺនៅពេលដែលព្រះរាជអាជ្ញាទទួលពាក្យបណ្តឹង ហើយលក្ខខណ្ឌនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវបានបំពេញ ព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ភ្លាម ហើយបញ្ជូនសំណុំរឿងនេះទៅយុត្តាធិការជំនុំជម្រះតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់សម្រាប់កោះហៅជនជាប់ចោទឲ្យចូលសវនាការដើម្បីធ្វើការជំនុំជម្រះ។ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវប្រគល់ឲ្យជនជាប់ចោទក្នុងថិរវេលានៃការកោះហៅមួយដែលកំណត់ដោយច្បាប់ និងស្របតាមរបៀបបែបបទនៃការប្រគល់មួយច្បាស់លាស់ជៀសវាងការបង្កើតឲ្យមានមោឃភាពនៃនីតិវិធី។

ថិរវេលានៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់៖ រយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឲ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ17។

-១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដី នៃទីស្នាក់ការរបស់តុលាការជាន់ដំបូង។

-២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ។

-២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា។

-៣ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។

របៀបនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់៖ ការប្រគល់ដីកាកោះ និងចុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវប្រគល់ឲ្យជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា។ ក្នុងករណីនេះព្រះរាជអាជ្ញាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដល់ជនជាប់ចោទ។ ព្រះរាជអាជ្ញាចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងកន្លែងប្រគល់ដីកានៅលើដីកាដើម។ ជនជាប់ចោទចុះហត្ថលេខានៅលើដីកាដើមនេះ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចត្រូវប្រគល់ដោយអាជ្ញាសាលាបានដែរ។ តាមមាត្រា៤៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងថា "អាជ្ញាសាលាត្រូវប្រើគ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះឲ្យជនជាប់ចោទដោយផ្ទាល់ដៃ"។ របៀបផ្សេងទៀតនៃការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចធ្វើឡើងតាមរយៈក្រឡាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត តាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ក្រឡាបញ្ជី អាជ្ញាធររដ្ឋបាល អាជ្ញាធរពន្ធនាគារ មន្ត្រីនគរបាលជាតិ ឬអាវុធហត្ថដែលព្រះរាជអាជ្ញាសុំឲ្យប្រគល់ដីការកោះបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវតែគោរពតាមបញ្ជារបស់ព្រះរាជអាជ្ញា18។

---

[17] មាត្រា ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[18] មាត្រា៤៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

## គ. ទម្រង់នៃដីកាបញ្ជូនរឿងទៅជម្រះផ្ទាល់

យោងតាមមាត្រា៤៦នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបាន កំណត់អំពីទម្រង់ របស់ដីកាបញ្ជូនរឿងទៅជម្រះផ្ទាល់។ ទម្រង់របស់ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់បានកំណត់នូវចំណុចជាផលប្រយោជន៍ដ៏សំខាន់ក្នុងកិច្ចជំនុំជម្រះហើយទម្រង់នៃដីកានោះរួមមានដូចជាៈ អត្តសញ្ញាណជនជាប់ចោទ សេចក្តីសង្ខេបនៃអង្គហេតុ ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

## ឃ. អានុភាពនៃការបញ្ជូនរឿងទៅជម្រះផ្ទាល់

ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ បានបង្កើតនូវអានុភាពមួយចំនួនរួមមាន ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ច និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចាំទី ។

- ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖ យើងបាននិយាយរួចទៅហើយទាក់ទងនឹងការបង្អាក់អាជ្ញាយុកាលនៃបទល្មើស។ បណ្តឹងអាជ្ញាមិនអាចធ្វើបានជាដាច់ខាត កាលបើវាផុតអាជ្ញាយុកាលសំរាប់ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ។ អាជ្ញាយុកាលចំពោះបទល្មើស នឹងត្រូវផ្តាច់កាលណាមានកិច្ចចោទប្រកាន់កើតមាន។ នេះជាសារៈសំខាន់ព្រោះថាបើមិនមានការចែងពីចំណុចនេះទេ អាជ្ញាយុកាលមិនត្រូវផ្តាច់ទោះបីបើមានការចោទប្រកាន់រួចហើយក៏ដោយ។ ដូច្នេះ អាចមានករណី នៅពេលបណ្តឹងបញ្ជូនទៅដលតុលាការហើយ តែបែរជារលត់បណ្តឹងអាជ្ញាទៅវិញករណីនេះតុលាការនឹងសម្រេចឲ្យជននោះរួចខ្លួន។ អាជ្ញាយុកាលចាប់រាប់ដោយគិតចាប់ពីពេលប្រព្រឹត្តបទល្មើស ដោយរយៈពេល ១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ឆ្នាំចំពោះបទមជ្ឈិម និង១ឆ្នាំចំពោះបទលហុ។
- ការផ្ទេរសមត្ថកិច្ចទៅតុលាការ៖ តាមមាត្រា២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងថា "អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់"។ ការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាកិច្ចចោទប្រកាន់មួយរបស់ព្រះរាជអាជ្ញាដែលជាតំណាងរបស់អង្គការអយ្យការ ដែលតាមរយៈដីកានេះ បាននាំឲ្យមានអវត្តមាននៃកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ តែវាបានផ្ទេរសមត្ថកិច្ចពី អយ្យការ ទៅយុត្តាធិការជំនុំជម្រះវិញ។
- ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ៖ យោងតាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានប្បញ្ញត្តិពីដែនកំណត់ចំពោះអង្គហេតុ។ ដែនកំណត់ចំពោះអង្គហេតុមានន័យថា តុលាការអាចជំនុំជម្រះបានត្រឹមអង្គហេតុដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ ដូចដែលបានឃើញពីការកំណត់ចំណុចមួយរបស់ទម្រង់ដីកា គឺកំណត់អំពីសេចក្តីសង្ខេបនៃអង្គហេតុ។ តុលាការមិនអាចលើកយកអង្គហេតុទាំងឡាយណាដែលមិនបានសរសេរក្នុងដីកានោះមកជំនុំជម្រះបានទេ។ ទោះជាមានការកំណត់អង្គហេតុរួចហើយក៏ដោយ តែជួនកាលមានករណីមួយចំនួន

ដែលតុលាការនឹងបង្គាប់ឲ្យបង្វិលសំណុំរឿងឲ្យព្រះរាជអាជ្ញាវិញ ដោយសារករណីបទមជ្ឈិម ឬបទលហុ ត្រូវជំនុំជម្រះដោយចៅក្រមទោល ឯករណីបទឧក្រិដ្ឋចាំបាច់ត្រូវជំនុំជម្រះជាក្រុមសមូហភាពដែលមានចៅក្រមបីរូប។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់នេះចេញក្នុងករណី ចោទប្រកាន់លើបទមជ្ឈិម ឬលហុ ដូចនេះបើតុលាការយល់ថា ជាបទឧក្រិដ្ឋវិញ នោះតុលាការនឹងបង្វិលសំណុំរឿងមកព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ចំណែកឯការកំណត់ដែនសមត្ថកិច្ចនៃការប្តឹងចំពោះបុគ្គលមានន័យថា តុលាការនឹងអាចជំនុំជម្រះចំពោះតែជនណាដែលបានចង្អុលឈ្មោះក្នុងដីកានេះតែប៉ុណ្ណោះ។ តុលាការមិនអាចធ្វើការជំនុំជម្រះលើជនទាំងឡាយណាដែលមិនមានការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះទេ។ គួរបញ្ជាក់ផងដែរថា ក្នុងករណីការចោទប្រកាន់ធ្វើឡើងដោយដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គ្មានអានុភាពបង្ខំឲ្យជនជាប់ចោទឲ្យចូលសវនាការទេ ជនជាប់ចោទមានសេរីភាពក្នុងការបង្ហាញខ្លួននៅមុខសវនាការ។

## ផ្នែកទី៣៖ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

នីតិវិធីនៃការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម គឺជានីតិវិធីដែលព្រះរាជអាជ្ញាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូងដោយផ្ទាល់។ នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនេះ ជានីតិវិធីដែលមានលក្ខណៈលឿនជាងនីតិវិធីផ្សេងទៀត វាជំរុញដំណើរការរឿងក្តីព្រហ្មទណ្ឌឲ្យបានឆាប់រហ័ស ជៀសវាងការកកស្ទះសំណុំរឿងនៅក្នុងស្ថាប័នតុលាការ ក៏ដូចជាដើម្បីសម្រួលដល់វិស័យយុត្តិធម៌ក្នុងតុលាការកម្ពុជាផងដែរ។ យ៉ាងណាមិញនីតិវិធីបង្ហាញខ្លួនភ្លាមនេះអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការបំពេញនូវលក្ខខណ្ឌមួយចំនួន ហើយដំណើរការប្រព្រឹត្តទៅស្របតាមនីតិវិធី និងឈានទៅដល់ការបង្កើតឲ្យមានអានុភាពមួយចំនួន។

### ក. លក្ខខណ្ឌនៃនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចជ្រើសយកនីតិវិធីនៃការចោទប្រកាន់ តាមរយៈការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខសាលាដំបូង ក្នុងករណីបើមានលក្ខខណ្ឌគ្រប់ដូចខាងក្រោម៖

បទល្មើសដាច់ខាតត្រូវតែជាបទមជ្ឈិមជាក់ស្តែង៖ បទល្មើសនេះបានបញ្ជាក់បង្ហាញយ៉ាងច្បាស់នៅក្នុងមាត្រា៨៦ និងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ដូច្នេះក្រៅពីបទមជ្ឈិមជាក់ស្តែង ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានឡើយ ឬអាចនិយាយម្យ៉ាងទៀតបានថា នីតិវិធីមួយនេះមិនអាចអនុវត្តបានឡើយ ចំពោះករណីបទឧក្រិដ្ឋ មជ្ឈិមមិនជាក់ស្តែង ឬបទលហុ។

បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ យ៉ាងតិច១ឆ្នាំ និងយ៉ាងច្រើន៥ឆ្នាំ៖ ពីរដំណាក់កាលគឺនីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា និងនីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ។

## ១. នីតិវិធីចាត់ការនៅចំពោះមុខព្រះរាជអាជ្ញា

ជាជំហានដំបូងគឺ ជនជាប់ចោទចាំបាច់ត្រូវតែជាជនដែលត្រូវបានឃាត់ខ្លួនតាមរយៈមាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បន្ទាប់ពីផុតរយៈពេលឃាត់ខ្លួនក្រោមការវិនិច្ឆ័យចំពោះមាត្រានេះ ចំពោះរយៈពេលឃាត់ខ្លួននោះ ព្រះរាជអាជ្ញាសម្រេចឲ្យមានការដោះលែងវិញ ឬព្រះរាជអាជ្ញាសម្រេចឲ្យមានការបញ្ជូនខ្លួនជននោះមក។ ក្នុងករណីដែលបញ្ជូនជននេះមក ព្រះរាជអាជ្ញា នឹងសម្រេចថាខ្លួននឹងប្រើនីតិវិធីណាមួយសម្រាប់ចោទប្រកាន់។ ក្នុងករណីដែលបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដែលអាចប្រើការបង្ហាញខ្លួនភ្លាមនេះ ព្រះរាជអាជ្ញានឹងធ្វើដូចតទៅ៖

ពិនិត្យអត្តសញ្ញាណរបស់ជនដែលត្រូវបានបញ្ជូនមក៖ ការធ្វើបែបនេះ ដើម្បីសម្គាល់ថានរណាជាជនល្មើស ហើយជននោះមានអត្តសញ្ញាណដូចអ្វីដែលកំណត់ហេតុបានកត់ត្រាឬទេ។

ត្រូវឲ្យដំណឹងដល់ជននោះអំពីរឿងហេតុដែលចោទប្រកាន់ និងឈ្មោះបទល្មើស៖ ការទទួលយកបែបនេះ ព្រោះវាជាសិទ្ធិរបស់ជនជាប់ចោទក្នុងការដឹងលឺអំពីមូលហេតុអ្វីដែលគេចោទមកខ្លួន នេះជាស្មារតីលើការទទួលស្គាល់លើសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។

ទទួលចម្លើយរបស់បុគ្គលនោះប្រសិនបើសាមីខ្លួនចង់និយាយ៖ នេះក៏ជាសិទ្ធិសេរីភាពរបស់ជនជាប់ចោទលើការអះអាងគ្រប់បែបយ៉ាង។ លើកយកព័ត៌មានគ្រប់យ៉ាងដែលខ្លួនបានដឹងជាផលប្រយោជន៍របស់ខ្លួន ។

ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម៖ ដើម្បីជាការចោទប្រកាន់ទៅតុលាការ ព្រះរាជអាជ្ញាត្រូវចេញកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមរួចបញ្ជូនទៅតុលាការជាន់ដំបូងដើម្បីចាត់តាំងចៅក្រមជំនុំជម្រះ (ដោយប្រធានតុលាការ) ក្នុងការបើកសវនាការ។ ក្នុងកំណត់ហេតុនេះចាំបាច់ត្រូវតែមានការចែងនូវចំណុច ដែលព្រះរាជអាជ្ញាបានប្រាប់ជនជាប់ចោទអំពីសិទ្ធិ ក្នុងការពឹងពាក់មេធាវីដែលអាចជ្រើសរើសដោយខ្លួនឯង ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្នុងករណីនេះមេធាវីត្រូវទទួលដំណឹងភ្លាមដើម្បីទទួលស្គាល់នូវសិទ្ធិមានរយៈពេលគ្រប់គ្រាន់ ដើម្បីការពារខ្លួនរបស់ជនជាប់ចោទ។

ទម្រង់ការដែលរៀបរាប់ខាងលើ ត្រូវតែចុះចូលកំណត់ហេតុ បើមិនដូចនេះទេនីតិវិធីត្រូវទុកជាមោឃៈ។ នៅពេលដែលកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមត្រូវបានធ្វើចប់សព្វគ្រប់រួចហើយ ជនជាប់ចោទនឹងត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពារ និងបញ្ជូនជននោះ ព្រមទាំងសំណុំរឿងទៅចំពោះមុខតុលាការ ដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង។

## ២. នីតិវិធីចាត់ការនៅចំពោះមុខយុត្តាធិការជំនុំជម្រះ

បន្ទាប់ពីតុលាការជាន់ដំបូងទទួលបណ្ដឹង តាមរយៈកំណត់ហេតុស្ដីពីការបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម។ តុលាការនឹងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទឲ្យច្បាស់លាស់ និងធ្វើរបាយការណ៍សង្ខេបអំពីអង្គហេតុដែលចោទប្រកាន់។ តុលាការប្រាប់ដល់ជនជាប់ចោទថា ខ្លួនអាចមានរយៈពេលសម្រាប់ការពារខ្លួនបន្ថែមទៀត។ ក្នុងករណីដែលជននោះសុំរយៈពេលការពារខ្លួន ឬតុលាការយល់ឃើញថារឿងក្ដីនោះមិនអាចទាន់ជំនុំជម្រះបានទេ ដោយសារមានសាលក្រមសំអាងហេតុ តុលាការអាចលើកទៅជំនុំជម្រះនៅពេលក្រោយបាន។ ហេតុដែលត្រូវសំអាងនេះ គឺជាមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដូចតទៅ៖

១-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី។

២-ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

៤-ដើម្បីរក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥-ដើម្បីការពារសន្តិភាពឱ្យជនត្រូវចោទ។

៦-ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។

តាមមាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា "តុលាការទាមទារក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួនដែរ ព្រោះដីកាសម្រេចពីការឃុំខ្លួនបណ្ដោះអាសន្នមានអានុភាពតែទៅលើជនជាប់ចោទនេះប៉ុណ្ណោះ ឯដីកាបង្គាប់ឲ្យឃុំខ្លួនមានអានុភាពជា ការបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួលយក និងឲ្យឃុំខ្លួនជននោះ"។ សាលក្រមលើអង្គសេចក្ដី ត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី២សប្ដាហ៍ គិតពីពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ការឃុំខ្លួនបណ្ដោះអាសន្នត្រូវបញ្ចប់ដោយពេញច្បាប់ក្រោយផុតរយៈពេលនេះ មានន័យថាជនជាប់ចោទនឹងត្រូវដោះលែងឲ្យមានសេរីភាព ព្រោះវិធានការឃុំខ្លួនបណ្ដោះអាសន្ន ជាវិធានការដែលបំពានដល់សិទ្ធិសេរីភាពរបស់មនុស្សយ៉ាងខ្លាំង ហើយម្យ៉ាងទៀតជននេះមិនទាន់ត្រូវបានផ្ដន្ទាទោសដោយតុលាការទេ។ ការឃុំខ្លួនរបស់នីតិវិធីនេះទាមទារនូវរយៈពេលកំណត់មួយដែរ ព្រោះដើម្បីធានាថាមិនមានការបំពានណាមួយហួសហេតុដល់សេរីភាពរបស់ជននោះទោះ ដោយសារការជំនុំជម្រះយឺតយ៉ាវ។

### ខ. អានុភាពនៃការបង្គាប់ឱ្យចូលខ្លួនភ្លាម

ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ជានីតិវិធីចោទប្រកាន់ដែលស្ដែងឡើងដោយកំណត់ហេតុ ឮស្ដីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ កំណត់ហេតុនេះមានអានុភាពដូចតទៅ៖

- ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖ ការចេញកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមដោយព្រះរាជអាជ្ញា គឺជាកិច្ចចោទប្រកាន់ជនល្មើស។ កិច្ចចោទប្រកាន់មានអានុភាពផ្តាច់អាជ្ញាយុកាលនៃបទល្មើសព្រហ្មទណ្ឌ។ មូលហេតុដែលនាំឲ្យមានការផ្តាច់អាជ្ញាយុកាល គឺដូចគ្នានឹងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរ។
- ការផ្ទេរសមត្ថកិច្ចតុលាការ៖ ជាការផ្ទេរសមត្ថកិច្ចពីអយ្យការ មកយុត្តាធិការជំនុំជម្រះតាមរយៈកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា ។ តុលាការនឹងគ្មានសមត្ថកិច្ចលើការជំនុំជម្រះ ប្រសិនបើមិនមានកិច្ចចោទប្រកាន់មកខ្លួន។
- ចំណងតុលាការចំពោះដែនបណ្តឹងចំពោះអង្គហេតុ និងបុគ្គល៖ កំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា គឺមានការកំណត់ពីអង្គហេតុ និងពីបុគ្គលដែលព្រះរាជអាជ្ញាចង់ធ្វើការចោទប្រកាន់ទៅលើ។ តុលាការអាចជំនុំជម្រះបានតែលើអង្គហេតុណាដែលមានចែងក្នុងកំណត់ហេតុនោះ ហើយអាចជំនុំជម្រះតែលើជនណាដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តែប៉ុណ្ណោះ។

# ជំពូកទី៣
# ការមិនចោទប្រកាន់របស់ព្រះរាជអាជ្ញា

ថ្វីបើច្បាប់បានប្រគល់នូវសិទ្ធិអំណាចជូនទៅដល់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ចំពោះជនទាំងឡាយណាដែលប្រព្រឹត្តិបទល្មើសក៏ពិតមែន ប៉ុន្តែនៅក្នុងលក្ខខណ្ឌមួយចំនួនច្បាប់ក៏តម្រូវឱ្យព្រះរាជអាជ្ញាធ្វើការលើកលែងចោទប្រកាន់បានបានផងដែរ។ នៅក្នុងស្ថានភាពខ្លះ ការចោទប្រកាន់មិនមែនជាដំណោះស្រាយល្អនោះទេ ប៉ុន្តែការលើកលែងមិនចោទប្រកាន់របស់ព្រះរាជអាជ្ញានេះ មិនមែនមានន័យថារឿងក្តីត្រូវបានបញ្ចប់ឡើយ។ កាលបើបណ្តឹងអាជ្ញាមិនទាន់រលត់ ព្រះរាជអាជ្ញានៅតែមានសិទ្ធិក្នុងការសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនដើម្បីការពារផលប្រយោជន៍ និងសណ្តាប់ធ្នាប់សាធារណៈជូនសង្គមជាតិជានិច្ច។

តើមានលក្ខខណ្ឌ និងមូលហេតុអ្វីខ្លះដែលច្បាប់ផ្តល់សិទ្ធអំណាចដល់ព្រះរាជអាជ្ញាធ្វើការលើកលែងចោទប្រកាន់? ក្រោយទទួលពាក្យបណ្តឹង និងធ្វើការស្រាវជ្រាវរកពត៌មាន ក៏ដូចជាភ័ស្តុតាង ដែលអាចបំពេញនូវលក្ខខណ្ឌក្នុងការលើកលែងចោទប្រកាន់នោះតំណាងអយ្យការអាចធ្វើការលើកលែងចោទប្រកាន់បានដោយអនុវត្តតាមនីតិវិធី ដែលច្បាប់បានកំណត់។

ជាបន្តទៅនេះ ដើម្បីធ្វើការបកស្រាយនូវបញ្ហាចោទខាងលើនេះឱ្យបានក្បោះក្បាយ យើងខ្ញុំនឹងធ្វើការបកស្រាយដោយបែងចែកជាបីផ្នែកផ្សេងគ្នាគឺះ

**ផ្នែកទី១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ**

**ផ្នែកទី២ នីតិវិធី ទម្រង់ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**

**ផ្នែកទី៣ យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ**

## ផ្នែកទី១៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ជាទូទៅ ការតម្កល់រឿងទុកឥតចាត់ការត្រូវតែអនុវត្តតាមច្បាប់ជាធរមាន។ មុនពេលចេញសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវតែថ្លឹងថ្លែងគិតគូរឱ្យបានល្អិតល្អន់គ្រប់ជ្រុងជ្រោយ រួមទាំងពិនិត្យទៅលើកាលៈទេសៈ និងស្ថានភាពទាំងឡាយនៃការប្រព្រឹត្តរបស់ជនល្មើស ដើម្បីជៀសវាងការសម្រេចសេចក្តីមិនបានត្រឹមត្រូវ ធ្វើឱ្យខាតបង់ប្រយោជន៍សាធារណៈ ជាពិសេសជនរងគ្រោះនៃរឿងក្តីផ្ទាល់តែម្តង។

ជាក់ស្តែង ព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការដោយប្រើឆន្ទានុសិទ្ធិរបស់ខ្លួន នៅពេលដែលបទល្មើសគ្រាន់តែជាបទមជ្ឈឹមតូចតាចមិនមានព្យសនកម្ម ឬបានផ្តល់ផ្តល់ព្យសនកម្មតិចតួចបំផុតដល់ជនរងគ្រោះ។ ក្នុងករណីខ្លះទៀត នៅពេលដែលដើមបណ្តឹងដាក់ពាក្យប្តឹងយឺតពេល(ផុតអាជ្ញាយុកាល) នោះក៏នាំឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការដែរ។

### ក. នត្ថិភាពនៃបទល្មើស

នត្ថិភាពនៃបទល្មើស សំដៅដល់រាល់អំពើដែលបានបង្កើតទៅជាព្យសនកម្ម ប៉ុន្តែមិនប្រាកដថាអំពើទាំងអស់នោះជាបទល្មើសព្រហ្មទណ្ឌនោះឡើយ។ បើយើងពិនិត្យទៅតាមគោលការនីត្យានុកូលភាព អំពើដែលជាបទល្មើស ទាល់តែអំពើនោះមានចែងក្នុងបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបអាចផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានន័យថា លុះណាតែច្បាប់បានចែងថាអំពើនោះជាបទល្មើស ទើបព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បាន។

#### ១. អវត្តមានបទល្មើស

អវត្តមាននៃបទល្មើស សំដៅដល់បណ្តឹងទាំងឡាយណាដែលធ្វើឡើងប្រឆាំងនឹងអំពើដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងការអនុវត្តជាក់ស្តែង មានពេលខ្លះអាចមានការភ័ន្តច្រលំរវាងរឿងរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ ក៏ប៉ុន្តែយើងគួរគប្បីកត់ចំណាំថា បណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌជាបណ្តឹងពីរផ្សេងគ្នា។ បណ្តឹងអាជ្ញាត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ក្នុងគោលបំណងស្វែងរក ហើយបង្ហាញឱ្យឃើញពីពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះតាមបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ចំណែកឯបណ្តឹងរដ្ឋប្បវេណីវិញ គឺមានគោលបំណងឱ្យសងនូវសំណងខូចខាតដែលបានកើតមានឡើងដោយសារអំពើល្មើសរបស់អ្នកប្រព្រឹត្ត។

#### ២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

ក្រោយពេលទទួលបានពាក្យបណ្តឹង ព្រះរាជអាជ្ញាអាចសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់បាន លុះណាតែបានបើកការស៊ើបអង្កេត ដើម្បីស្វែងរកធាតុផ្សំនៃបទល្មើសគឺ ធាតុនីត្យានុកូល ធាតុសត្យានុម័ត

និងធាតុអត្តនោម័ត។ ក្នុងករណីរឿងក្តីមិនបានបំពេញនូវធាតុផ្សំទាំងបីនៃបទល្មើសទាំងបីទេនោះ ព្រះរាជអាជ្ញាត្រូវចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### ខ. មូលហេតុគតិយុត្ត

#### ១. ការរលត់បណ្តឹងអាជ្ញា

យោងតាមបទបញ្ញត្តិមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បណ្តឹងអាជ្ញាត្រូវបានរលត់ដោយមូលហេតុ៖

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និង
- អាជ្ញាអស់ជំនុំ។

ក្រៅពីមូលហេតុខាងលើនេះ មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ក៏បានបញ្ញត្តិពីមូលហេតុផ្សេងទៀតនៃការរលត់នូវបណ្តឹងអាជ្ញាដែរ ដោយមានសេចក្តីថា៖ កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ គឺមាន៖

- ការសម្របសម្រួលជាមួយរដ្ឋ
- ការដកពាក្យប្តឹង ក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ការបង់ប្រាក់ពិន័យសរុប ឬបង់ប្រាក់សម្របសម្រួល

ដោយផ្អែកលើមូលហេតុដែលបានរៀបរាប់ខាងលើនេះ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់ខាងបទព្រហ្មទណ្ឌបានទៀតទេ ព្រោះបណ្តឹងអាជ្ញាត្រូវបានរលត់ហើយ។ ប៉ុន្តែយើងគួរកត់ចំណាំថា ក្នុងករណីបណ្តឹងអាជ្ញាត្រូវបានរលត់នេះ មិនមែនបានសេចក្តីថាបណ្តឹងរដ្ឋប្បវេណីត្រូវបានរលត់ដែរនោះទេ។ បណ្តឹងរដ្ឋប្បវេណីនៅតែអាចបន្តទៀតបានជាមួយនឹងសន្តតិជនរបស់ជនល្មើស។

#### ២. មូលហេតុគតិយុត្តផ្សេងៗទៀត

បណ្តឹងអាជ្ញាអាចផុតរលត់ ហើយតំណាងអយ្យការនឹងធ្វើការលើកលែងចោទប្រកាន់ ដោយផ្អែកលើមូលហេតុគតិយុត្តផ្សេងៗទៀតដូចជា៖

- **អភ័យឯកសិទ្ធិ៖** សំដៅដល់លក្ខខណ្ឌពិសេសដែលច្បាប់ផ្តល់ឱ្យបុគ្គលមួយចំនួន ទាក់ទងនឹងកិច្ចនីតិវិធី ការទទួលខុសត្រូវ ឬការទទួលបាននូវស្ថានសម្រាលទោសពីការប្រព្រឹត្តបទល្មើសណាមួយ។ ការលើកលែងចោទប្រកាន់ចំពោះបុគ្គលដែលមានអភ័យឯកសិទ្ធិ មិនមែនស្ថិតក្នុងមូលហេតុនៃការរលត់បណ្តឹងអាជ្ញាឡើយ ពោលគឺវាគ្រាន់តែជាមូលហេតុគតិយុត្តផ្សេងទៀតដែលអនុញ្ញាតឱ្យតំណាង

អយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការតែប៉ុណ្ណោះ។ នៅប្រទេសកម្ពុជាយើង អភ័យឯកសិទ្ធិនេះបានផ្តល់ទៅឱ្យបុគ្គលមួយចំនួនប៉ុណ្ណោះ មានដូចជា៖ ព្រះមហាក្សត្រ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា តំណាងទូត -ល- ។

- **អនិយ័តភាពនៃនីតិវិធី៖** សំដៅដល់ភាពមិនស្របច្បាប់នៃនីតិវិធីក្នុងដំណើរប្រតិបត្តិការរបស់ព្រះរាជអាជ្ញា ឬនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែម។
- **ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស៖** មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និងមាត្រា៣៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១០ បានកំណត់ចែងដោយមិនអនុញ្ញាតិឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ចំពោះអំពើល្មើសមួយចំនួនឡើយ។ អំពើល្មើសមួយចំនួននោះមានដូចជា៖

- វិប្បល្លាស្មារតី
- ការអនុញ្ញាតិដោយច្បាប់ ឬអាជ្ញាធរ
- ការការពារខ្លួនស្របច្បាប់ (ការការពារធម្មានុរូប)
- សច្ចាធារណ៍ នៃការការពារខ្លួនស្របច្បាប់
- ស្ថានភាពចាំបាច់
- ការបង្ខិតបង្ខំ
- អនីតិជន (អាយុក្រោម១៤ឆ្នាំ) -ល-។

ក៏ប៉ុន្តែយើងគួរកត់ចំណាំថា ការរួចផុតពីការចោទប្រកាន់នេះមិនមែនមានន័យថាបណ្តឹងអាជ្ញាត្រូវបានរលត់ទេ។

## គ. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

នៅក្នុងស្ថានភាពខ្លះ ព្រះរាជអាជ្ញាលើកលែងចោទប្រកាន់ដោយសារតែការចោទប្រកាន់នោះមិនមានផ្តល់ផលប្រយោជន៍អ្វីសោះដល់សាធារណៈ និងដើមបណ្តឹង។ ការចោទប្រកាន់ដែលមិនផ្តល់ផលប្រយោជន៍អាចបណ្តាលមកពីមូលហេតុផ្សេងៗដូចជា៖

- ការស្វែងរកមិនបានផលប្រយោជន៍
- ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង
- ស្ថានភាពវិប្បល្លាស្មារតីដែលបន្ថយការយល់ដឹងរបស់ជនល្មើស
- ការខកខានរបស់ដើមបណ្តឹង
- អាកប្បកិរិយារបស់ជនរងគ្រោះ
- ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

- ព្យសនកម្ម ឬការរំខានតិចតួចដែលបានបង្កដោយជនល្មើស ជាអាទិ៍។

# ផ្នែកទី២៖ នីតិវិធី ទម្រង់ការ និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

## ក. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

យោងតាមបទបញ្ញត្តិមាត្រា៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក្នុងករណីសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្ដឹងដោយបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម រួចត្រូវបញ្ជាក់ពីសំអាងហេតុ និងសំអាងច្បាប់ជាលាយលក្សណ៍អក្សរនៅក្នុងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួន រួចផ្ដល់ដំណឹងដល់ដើមបណ្ដឹងក្នុងរយៈពេលខ្លីបំផុត យ៉ាងយូរបំផុតត្រឹមរយៈពេល២(ពីរ)ខែ គិតពីថ្ងៃចុះបញ្ជីពាក្យបណ្ដឹង។

## ខ. ទម្រង់ការនៃការតម្កល់រឿងទុកឥតចាត់ការ

ដូចបានបញ្ជាក់ខាងលើរួចជាស្រេចហើយគឺ មុននឹងចេញដីការសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវបញ្ជាក់ពីសំអាងហេតុ និងសំអាងច្បាប់ជាលាយលក្សណ៍អក្សរនៅក្នុងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួន។ សំអាងហេតុ និងសំអាងច្បាប់នេះហើយគឺជាទម្រង់ការនៃការតម្កល់រឿងទុកឥតចាត់ការ។

- សំអាងហេតុ៖ សំដៅដល់ការលើកយកអង្គហេតុទាំងឡាយដែលពាក់ព័ន្ធមកធ្វើជាសំអាង ដែលជាមូលហេតុធ្វើឱ្យមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ។
- សំអាងច្បាប់៖ សំដៅដល់ការលើកយកអត្ថបទច្បាប់ដែលគាំទ្រដល់អង្គហេតុ និងជាមូលហេតុដែលធ្វើឱ្យ ព្រះរាជអាជ្ញាការសម្រេចចិត្តតម្កល់រឿងទុកឥតចាត់ការ។

## គ. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការមិនមានអានុភាពធ្វើឱ្យមានអាជ្ញាអស់ជំនុំទេ។ តើអ្វីទៅជាអាជ្ញាអស់ជំនុំ?

មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិថា៖ ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាកាសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់បានទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។

ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការ មិនមានអានុភាពធ្វើឱ្យមានអាជ្ញាអស់ជំនុំ មានន័យថាក្រោយពេលព្រះរាជអាជ្ញាបានចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ជនល្មើសនៅតែអាចទទួលនូវការចោទប្រកាន់សារជាថ្មីដដែល។

## ផ្នែកទី៣ យន្តការជម្រុញឱ្យមានការចោទប្រកាន់ឡើងវិញ

### ក. ការសើររើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា

ការសើររើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា អាចធ្វើឡើងក្នុងខណៈពេលដែលបណ្តឹងអាជ្ញាមិនទាន់រលត់តែប៉ុណ្ណោះ។ ដូចនេះមានន័យថា ប្រសិនបើការលើកលែងចោទប្រកាន់របស់ព្រះរាជអាជ្ញាបានធ្វើឡើងដោយមូលហេតុផុតរលត់នៃបណ្តឹងអាជ្ញា នោះព្រះរាជអាជ្ញាមិនអាចសើររើកែប្រែសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការបានឡើយ។

ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាអាចសើររើកែប្រែសេចក្តីសម្រេចរបស់ខ្លួនបានដោយសារករណីមានកំហុសឆ្គងកើតមានឡើងដូចជា មានអង្គហេតុថ្មីត្រូវបានរកឃើញ មានភ័ស្តុតាង ឬមានចន្លោះប្រហោងណាមួយនៃនីតិវិធី។

### ខ. បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

ដើមបណ្តឹងមានសិទ្ធិប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រសិនបើខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការដែលធ្វើឡើងដោយតំណាងអយ្យការអមសាលាដំបូងទេនោះ។ ការប្តឹងតវ៉ានេះត្រូវធ្វើក្នុងកំឡុងពេល២(ពីរ)ខែ បន្ទាប់ពីសាមីខ្លួនដែលជាម្ចាស់បណ្តឹងបានទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការប្តឹងតវ៉ានេះដែរ ត្រូវធ្វើឡើងតាមបណ្តឹងសាមញ្ញនៅអង្គការអយ្យការដែលពាក់ព័ន្ធ បន្ទាប់មកសំណុំរឿងនឹងត្រូវបញ្ជូនភ្លាមទៅឱ្យសាលាឧទ្ធរណ៍ដែលមានសមត្ថកិច្ចតែម្តង។

ចំពោះការប្តឹងតវ៉ានេះ អាចទទួលបានការយល់ព្រម ឬការបដិសេធ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ជូនដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់ ប្រសិនបើខ្លួនយល់ឃើញថាការតវ៉ានេះមានមូលហេតុត្រឹមត្រូវ។ ផ្ទុយទៅវិញ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បានពិនិត្យ និងយល់ឃើញថាការតវ៉ាមិនមានមូលហេតុត្រឹមត្រូវ នោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ចាត់ទុកជាបានការ រួចផ្តល់ដំណឹងអំពីសេចក្តីសម្រេចនេះជូនទៅអ្នកប្តឹងវិញ។

### គ. អំណាចអធិបញ្ញាដោយឋានានុក្រមនៃអង្គការអយ្យការ

យោងតាមបទបញ្ញត្តិ មាត្រា២៩ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជា លាយលក្ខណ៍អក្សរដែល ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឲ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេ

ចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាឲ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឲ្យចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាកាគួរ។

ព្រះរាជអាជ្ញា៖ ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញាឲ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណា ដែលខ្លួនយល់ឃើញថាជាការគួរ។

ព្រះរាជអាជ្ញារង៖ ព្រះរាជអាជ្ញារង គឺជាចៅក្រមអយ្យការដែលនៅអមសាលាដំបូងរាជធានី-ខេត្ត មានឋានានុក្រមក្រោមគេព្រះរាជអាជ្ញា ប៉ុន្តែគាត់អាចប្រើអំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងចោទប្រកាន់។ នៅពេលដែលមានអធិបញ្ញាឱ្យតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញារងត្រូវតែធ្វើតាមអធិបញ្ញានេះ។

## ឃ. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

តាមរយៈបទបញ្ញត្តិមាត្រា១៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ យើងឃើញថា ចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទៅព្រះរាជអាជ្ញា។ ក្រោយពីបានទទួលពាក្យបណ្តឹង ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចោទទៅលើបុគ្គលម្នាក់ ឬច្រើននាក់ក៏ដោយ។

ព្រះរាជអាជ្ញាអាចសុំចៅក្រមកុំឱ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាបានផុតរលត់ ឬអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចសម្រេចបើកការស៊ើបសួរ ឬសម្រេចមិនបើកការស៊ើបសួរ។

ក្នុងករណីចៅក្រមស៊ើបសួរ សម្រេចមិនបើកការស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសម្អាងហេតុ ហើយត្រូវបញ្ជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ដោយឡែក ក្នុងករណីដែលចៅក្រមស៊ើបសួរ នៅតែសម្រេចបើកការស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសម្អាងហេតុ ហើយត្រូវបញ្ជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា៕

# សន្និដ្ឋាន និងអនុសាសន៍

លទ្ធផលដែលទទួលបានមកពីកិច្ចការស្រាវជ្រាវលើប្រធានបទ **នីតិវិធីព្រហ្មទណ្ឌក្នុងដំណាក់កាលអយ្យការ** បានបង្ហាញឱ្យឃើញថា ចំណាត់ការក្នុងរឿងក្តីព្រហ្មទណ្ឌនីមួយៗដែលធ្វើឡើងដោយព្រះរាជអាជ្ញា ពិតជាមានភាពស្មុគស្មាញ ទាមទារឱ្យមានការសិក្សា ស្រាវជ្រាវ ត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន និងហ្មត់ចត់បំផុត ដើម្បីធានាបាននូវភាពយុត្តិធម៌ជូនដល់ជនរងគ្រោះ និងសង្គមជាតិទាំងមូល។

ការសម្រេចចោទប្រកាន់ ឬលើកលែងចោទប្រកាន់របស់ព្រះរាជអាជ្ញា មានអានុភាពធំធេងណាស់ដល់ផលប្រយោជន៍នៃភាគីបណ្តឹង ពោលគឺអាចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិបុគ្គល ប្រសិនបើមានការសម្រេចសេចក្តីខុស។ ព្រោះថា ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ មានអានុភាពធ្វើឱ្យដាក់ជនណាម្នាក់ ឬច្រើននាក់ឱ្យស្ថិតក្រោមការពិនិត្យអំពីបទល្មើស ដែលក្នុងស្ថានភាពនោះនាំឱ្យបុគ្គលអ្នកប្រព្រឹត្តិ ក្លាយខ្លួនជាជនល្មើស និងលើសពីនេះនឹងអាចឈានទៅដល់ការដកហូតសិទ្ធិ សេរីភាពជាប្រជាពលរដ្ឋ ដោយមានទោសត្រូវបង់ប្រាក់ពិន័យ និងជាប់ពន្ធធនាគារទៀតផង។ ដោយឡែក ក្នុងករណីលើកលែងចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការវិញ ប្រសិនបើព្រះរាជអាជ្ញាមានការធ្វេសប្រហែស មិនបានស្រាវជ្រាវឱ្យបានល្អិតល្អន់ ហើយសម្រេចសេចក្តីមិនបានត្រឹមត្រូវ នោះជនដែលប្រព្រឹត្តអំពើល្មើសច្បាប់នឹងត្រូវបានរួចខ្លួន ដែលជាហេតុនាំឱ្យជនរងគ្រោះទទួលរងនូវភាពអយុត្តិធម៌។ ដោយសារតែហេតុផលទាំងនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងបានកំណត់នូវបទបញ្ញត្តិជាច្រើនសម្រាប់តំណាងអយ្យការក្នុងការអនុវត្តតាម ដើម្បីជៀសវាង និងកាត់បន្ថយការកើតមានឡើងនូវកំហុសផ្សេងៗក្នុងការចេញសេចក្តីសម្រេចចោទប្រកាន់ជនណាម្នាក់ ឬច្រើននាក់ ឱ្យជាប់ទោស ឬលើកលែងចោទប្រកាន់។ ជាក់ស្តែង ដូចដែលយើងបានឃើញហើយក្នុងកថាខណ្ឌទី២ មាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមជាមុនសិន មុននឹងធ្វើការសម្រេចចោទ ឬមិនចោទប្រកាន់។ លើសពីនេះក្រមព្រហ្មទណ្ឌ ក៏បានបញ្ញត្តិនូវលក្ខខណ្ឌទម្រង់ និងមូលហេតុមួយចំនួនសម្រាប់ព្រះរាជអាជ្ញាយកទៅវិនិច្ឆ័យ និងអនុវត្តកិច្ចការរបស់ខ្លួនតាមនោះផងដែរ។

ជាសរុបមក ក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា ជាអ្នកការពារផលប្រយោជន៍រួមដល់សាធារណៈ ក៏ដូចជាសង្គមជាតិទាំងមូល ព្រះរាជអាជ្ញា ឬតំណាងអយ្យការត្រូវតែបំពេញកិច្ចការរបស់ខ្លួនដោយយកចិត្តទុកដាក់ មានការប្រុងប្រយ័ត្នខ្ពស់ ដោយអនុលោមយ៉ាងខ្ជាប់ខ្ជួនស្របតាមស្មារតី និងនីតិវិធីនៃច្បាប់។ លើសពីនេះ គឺត្រូវតែអនុវត្តវិជ្ជាជីវៈរបស់ខ្លួនឱ្យបានត្រឹមត្រូវ សុក្រឹត្យ យុត្តិធម៌ ដោយផ្អែកលើគោលការណ៍គតិទាំងប្រាំគឺៈ វិរិយសម្បយុត្ត សុចរិតយុត្តិធម៌ បញ្ញត្តិគារវៈ សមទណ្ឌោ និងបញ្ញាវុធវិនិច្ឆ័យ៕

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ (បច្ចុប្បន្ន)
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ២០០៧
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤
- គោលការណ៍ណែនាំស្តីពី "តួនាទីរបស់ព្រះរាជអាជ្ញា" អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧

# ឧបសម្ព័ន្ធ

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**
**សាលាដំបូងខេត្តកណ្ដាល**

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

សំណុំរឿងព្រហ្មទណ្ឌលេខ ៧០៥ អ.ក
ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៩
លេខ៖ ដកសស/១៩

យើង ............................. តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

បានឃើញរបាយការណ៍លេខ ០៦៣ របក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១ របស់ ការិយាល័យចរាចរណ៍ផ្លូវគោក នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មតបានថា ៖

| | | |
|---|---|---|
| នាមត្រកូល | ៖ | .................. នាមខ្លួន៖ ..................... នាមហៅក្រៅ៖ ......... ភេទ៖.......... |
| អាយុ | ៖ | .........ឆ្នាំ |
| ទីកន្លែងកំណើត | ៖ | ............................................................................................ |
| ទីលំនៅបច្ចុប្បន្ន | ៖ | ............................................................................................ |
| មុខរបរ | ៖ | ........................................... |
| ស្ថានភាពគ្រួសារ | ៖ | រៀបការ/នៅលីវ (ប្ដី/ប្រពន្ធឈ្មោះ ៖ .................."រស់/ស្លាប់" មានកូន៖...... |

បានប្រព្រឹត្តអំពើដូចតទៅ៖

កាលពីថ្ងៃទី ២៣ខែ មិនា ឆ្នាំ ២០១៩ វេលាម៉ោង ១៧ និង ៣០ នាទី នៅលើផ្លូវជាតិលេខ២១ ត្រង់ចំនុច ភូមិព្រៃកខ្សេវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល មានម៉ូតូមួយគ្រឿងម៉ាក HONDA C125 ពណ៌ខ្មៅ ពាក់ផ្លាកលេខភ្នំពេញ 1C-XXXX បើកបរដោយឈ្មោះ................. ហើយនៅពេលបើកបរមកដល់ចំណុចភូមិព្រៃកខ្សេវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល ក៏បានជ្រុលទៅបុកជាមួយនឹងម៉ូតូមួយគ្រឿងម៉ាក HONDA C125 ពាក់ផ្លាកលេខកណ្តាល 1AD-XXXX បើកបរដោយឈ្មោះ .................រួមដំណើរដោយឈ្មោះ.................ក្នុងទិសដៅផ្ទុយគ្នា បណ្តាលឱ្យភាគីទាំងសងខាងមានឈ្មោះ ........................................... រងរបួស។

អំពើខាងលើជាបទល្មើស៖

**បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅលើផ្លូវជាតិលេខ២១ ត្រង់ចំនុច ភូមិព្រៃកខ្សេវ សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ២០១៩ តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ ផ្លូវគោក។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**សម្រេច៖**

**បើកការស៊ើបសួរលើអង្គហេតុខាងលើ និង ៖**

☐ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ

ឈ្មោះ ...................... ភេទស្រី អាយុ ២៧ឆ្នាំ (ក្រៅឃុំ)

☐ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនជាបណ្តោះអាសន្ន

ឈ្មោះ ...................... ភេទស្រី អាយុ ២៧ឆ្នាំ (ក្រៅឃុំ)

ថ្ងៃសុក្រ ១១រោច ខែ កត្តិក ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

កណ្តាល, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៥៣ អក.

ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩

# ដីកាកោះ

**យើង ................................ តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។**

អញ្ជើញឈ្មោះ ................................ ភេទប្រុស ជាជនសង្ស័យ មានទីលំនៅបច្ចុប្បន្នភូមិកំពុងពោធិ៍ ឃុំក្រាំងយ៉ូវ ស្រុកកោះធំ ខេត្តកណ្ដាល។

ឲ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី...........ខែ.............ឆ្នាំ២០១៩ វេលាម៉ោង................ព្រឹក/ រសៀល។

ដើម្បីសាកសួរពីដំណើររឿងពាក់ព័ន្ធនឹងបណ្ដឹងរបស់ឈ្មោះ ........................... ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩ ប្ដឹងអ្នកពីបទ ឆបោក។

សាមីខ្លួនត្រូវអញ្ជើញមកតាមដីកាកោះនេះ អោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

កណ្ដាល, ថ្ងៃទី .......... ខែ វិច្ឆិកា ឆ្នាំ២០១៩

**តំណាងអយ្យការ**

យើង..................................បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ...........................មានទីលំនៅបច្ចុប្បន្ន នៅភូមិ.....................ឃុំ-សង្កាត់........................ក្រុង-ស្រុក-ខណ្ឌ.......................ខេត្ត-រាជធានី ....................នៅថ្ងៃទី........ខែ..............ឆ្នាំ.................ផ្ទាល់រួចរាល់ហើយ ដោយយើងបានទុកចុងដីកានេះ មួយច្បាប់អោយសាមីខ្លួន ហើយប្រាប់ថាអោយសាមីខ្លួន ប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជី នៅពេលខ្លួនចូលទៅដល់តុលាការ ឬអយ្យការ ។

**អ្នកទទួលលិខិត** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្តាល**

# ដីកាបញ្ជាឲ្យចូលខ្លួន

លេខៈ **០២០** ដកបចខ/១៧

យើង ...................... តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញមាត្រា ៣៧ មាត្រា ៩៤ និងមាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/របក/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៧៦៧ អ.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញដីកាកោះលើកទី១ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧ លើឈ្មោះ ................ ភេទ ប្រុស អាយុ ២៨ ឆ្នាំ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញដីកាកោះលើកទី២ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៧ លើឈ្មោះ ................. ភេទ ប្រុស អាយុ ២៨ ឆ្នាំ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

## បញ្ជាៈ

| | |
|---|---|
| នាមត្រកូល | ៖ ...... នាមខ្លួន៖ ......... នាមហៅក្រៅ៖ ...... ភេទ៖ប្រុស |
| អាយុ | ៖ ២៨ឆ្នាំ |
| ទីកន្លែងកំណើត | ៖ ភូមិត្រពាំងអំពិល ឃុំពន្សាំង ស្រុកអង្គស្នួល ខេត្តកណ្តាល |
| ទីលំនៅបច្ចុប្បន្ន | ៖ ភូមិទួលស្រម៉ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល |

មុខរបរ ៖ .......................

ស្ថានភាពគ្រួសារ ៖ រៀបការ(ប្រពន្ធឈ្មោះ៖ ............. "រស់" កូន៖ ០១ នាក់)

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ................ "រ/ស " ម្តាយឈ្មោះ៖ .................. "រ/ស" ជានីតិជន។

១-ចូលបង្ហាញខ្លួននៅ អយ្យការអមសាលាដំបូងខេត្តកណ្តាលចាប់ពីថ្ងៃទី **១៤** ខែ **សីហា** ឆ្នាំ **២០១៧** ដល់ថ្ងៃទី **១២** ខែ **កញ្ញា** ឆ្នាំ **២០១៧** នៅរៀងរាល់ម៉ោងធ្វើការ ដើម្បីសាកសួរពីបណ្តឹងព្រហ្មទណ្ឌពីបទ **រំលោភលើទំនុកចិត្ត** និងបទ**ក្លែងបន្លំ**។

២-បង្គាប់មកលោកអធិការនគរបាលស្រុកអង្គស្នួល អនុវត្តដីកានេះ។

កណ្តាល, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧

**តំណាងអយ្យការ**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**
**សាលាដំបូងខេត្តកណ្តាល**

លេខៈ **៣៥៤** ដកសសប/១៧

## ដីកាស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម

យើង.................... តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល

-បានឃើញមាត្រា ១៣២ និងមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៣ អ.ក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៦

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៥៨០ ដកសស/១៦ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល

-បានឃើញសំណុំរឿងស៊ើបសួរលេខ ០៧៤ សស ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧ របស់ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល

-បានឃើញដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យមូលលេខ ៤១៨ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថាៈ**

តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៥៨០ ដកសស/១៦ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ របស់តំណាងអយ្យការបានចោទប្រកាន់លើ **អញ្ញាតជន** ដោយបានដាក់ឲ្យស្ថិតនៅក្រោមពិនិត្យពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ដោយក្រោយពីការស៊ើបសួរមានតម្រុយបទល្មើសលើឈ្មោះ ............................. ។

**ហេតុដូច្នេះ**

ស្នើសុំលោកចៅក្រមស៊ើបសួរ៖

១-ធ្វើការស្រាវជ្រាវសាវតាជាតិទៅលើឈ្មោះ ......................... ។

២-បន្តការស៊ើបសួរដើម្បីចាត់ការតាមនីតិវិធី។

កណ្ដាល, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្តាល**

លេខ ៣៧៥ រ.ប/១៤

# អយ្យការអមសាលាដំបូងខេត្តកណ្តាល

**<u>ជម្រាបមក</u>**

# លោកអធិការនគរបាលស្រុកអង្គស្នួល

**កម្មវត្ថុ៖** ស្នើសុំធ្វើការស៊ើបអង្កេតបឋមពាក់ព័ន្ធនឹងករណី **ញុះញង់ឲ្យប្រព្រឹត្តបទល្មើស បទគំរាមកំហែងថានឹងធ្វើឲ្យខូចខាត និងបទធ្វើឲ្យខូចខាតដោយចេតនា** កាលពីថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤ ប្រព្រឹត្តនៅមុខរោងចក្រលាំង ជី អ៊ិនដាស្ទ្រី ខេម បូឌា ស្ថិតនៅភូមិព្រៃស្វាយ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។

**យោង៖** -សំណុំរឿងព្រហ្មទណ្ឌលេខ ៧៨២ អ.ក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-ពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ របស់មេធាវីឈ្មោះ ..........

តបតាមកម្មវត្ថុ និងយោងខាងលើ តំណាងអយ្យការសូមជម្រាបមក លោកអធិការថា តំណាងអយ្យការបានផ្តើមបើកការស៊ើបអង្កេតបឋមលើសំណុំរឿងព្រហ្មទណ្ឌលេខ៧៨២ អ.ក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ប៉ុន្តែតំណាងអយ្យការនៅតែពិនិត្យឃើញថាមានចំនុច ស្មុគស្មាញមួយចំនួនក្នុងការស៊ើបអង្កេតលើសំណុំរឿង

ព្រហ្មទណ្ឌនេះ គប្បីមានការសហការពីមន្ត្រីនគរបាលមូលដ្ឋានក្នុងកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងបទល្មើសខាងលើ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកអធិការនគរបាលស្រុកអង្គស្នួល មេត្តាបើកការស៊ើបអង្កេតបឋមលើបទល្មើសខាងលើនេះ រួចធ្វើរបាយការណ៍សរុបនៃការស៊ើបអង្កេតនេះ មកអយ្យការអមសាលាដំបូងខេត្តកណ្តាលវិញ ឲ្យបានចាប់របស់តាមការគួរ។

សូម **លោកអធិការ** មេត្តាទទួលនូវការរាប់អានអំពីរូបខ្ញុំ ។

កណ្ដាល, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្ដាល

លេខ ០០២ ដកឆធ/១៤

# តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**<u>ជម្រាបមក</u>**

## លោកប្រធានសាលាដំបូងខេត្តកណ្ដាល

**កម្មវត្ថុ:** សំណើសុំចេញដីកាបង្គាប់ឲ្យឆែកឆេរឃ្លាំងក្នុងដីឡូត៍គ្មានលេខ ផ្លូវជាតិលេខ២១A ស្ថិតនៅភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល ពីបទនាំចូល ស្តុក ចែកចាយ សារធាតុគីមីគ្រប់ប្រភេទ គ្មានច្បាប់អនុញ្ញាត។

**យោង:** -មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-លិខិតលេខ ២០៤ /១៤សក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ របស់នាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបលោកប្រធានសាលាថា អគ្គស្នងការរង និងជាប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចបានស្នើសុំឲ្យអយ្យការអមសាលាដំបូង ខេត្តកណ្ដាល ដើម្បីផ្ដល់ដីកាបង្គាប់ឲ្យឆែកឆេរឃ្លាំងក្នុងដីឡូត៍គ្មានលេខ ផ្លូវជាតិលេខ២១A ស្ថិតនៅភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល ពីបទនាំចូល ស្តុក ចែកចាយ សារធាតុគីមីគ្រប់ប្រភេទ គ្មានច្បាប់អនុញ្ញាត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**លោកប្រធាន** ជួយចេញដីកាបង្គាប់ឲ្យឆែកឆេរឃ្លាំងក្នុងដីឡូត៍គ្មានលេខ ផ្លូវជាតិលេខ២១A ស្ថិតនៅ ភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល ពីបទនាំចូល ស្តុក ចែកចាយ សារធាតុគីមីគ្រប់ប្រភេទ គ្មានច្បាប់អនុញ្ញាត ដើម្បីឲ្យខ្ញុំមានលទ្ធភាពចាត់ការតាមច្បាប់។

សូម **លោកប្រធាន** ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

កណ្ដាល,ថ្ងៃទី ០៩ មេសា ឆ្នាំ ២០១៤

**ព្រះរាជអាជ្ញា**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# <u>ពាក្យសុំដកពាក្យបណ្តឹង</u>

នាងខ្ញុំឈ្មោះ ........................... ភេទ......... អាយុ...........ឆ្នាំ មានទីលំនៅ ...........................................................ទូរស័ព្ទលេខ..................។

**សូមគោរពចូលមក**

**លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្តាល**

<u>មេត្តាជ្រាបថា។</u>

**កម្មវត្ថុ៖** សំណើសុំដកពាក្យបណ្តឹងឈប់ប្តឹងមកលើឈ្មោះ ................ ភេទប្រុស អាយុ ២៦ឆ្នាំ ។

**យោង៖** -សំណុំរឿងព្រហ្មទណ្ឌលេខ ៦៤៦ អ.ក ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល

-ពាក្យបណ្តឹងចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៧ របស់ឈ្មោះ ......................... ភេទស្រី អាយុ ៤២ឆ្នាំ ។

តបតាមកម្មវត្ថុ និងយោងខាងលើនេះ នាងខ្ញុំបានប្តឹងពីឈ្មោះ ................................ ភេទប្រុស អាយុ ២៦ឆ្នាំ ពីបទ**បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន បណ្តាលឲ្យស្លាប់ដល់អ្នកដទៃ ដោយអចេតនា** ប្រព្រឹត្តនៅលើផ្លូវជាតិលេខ៣ ចន្លោះគីឡូម៉ែត្រលេខ ៣១-៣២ ក្នុងភូមិតាឡឹក ឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៧ បណ្តាលឲ្យប្តីរបស់នាងខ្ញុំឈ្មោះ .......................... ស្លាប់ បាត់បង់ជីវិត។ ប៉ុន្តែដោយហេតុថា ភាគីខាងជនបង្ករហេតុបានជួយបង់ថ្លៃព្យាបាលជម្ងឺមកឲ្យនាងខ្ញុំលើសពីនេះភាគីទាំងសងខាងក៏បាន

ព្រមព្រៀងគ្នាបញ្ចប់វិវាទពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍រួចរាល់ អស់ហើយ។ ម្យ៉ាងវិញទៀតនាងខ្ញុំពុំមានពេលវេលាគ្រប់គ្រាន់ និងរវល់រកស៊ីចិញ្ចឹមគ្រួសារផង ហេតុដូច្នេះនាងខ្ញុំជាដើមបណ្ដឹងសុំអនុញ្ញាតិដកពាក្យបណ្ដឹងប្ដឹងពីឈ្មោះ ......................... ភេទប្រុស អាយុ ២៦ឆ្នាំ ចាប់ពីពេលនេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោកព្រះរាជអាជ្ញា មេត្តាទទួលពិនិត្យ និងសម្រេចទៅតាមពាក្យស្នើសុំរបស់នាងខ្ញុំដោយសេចក្ដីអនុគ្រោះផង។

សូមលោក **ព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ៕

កណ្ដាល,ថ្ងៃទី ...... ខែ មិថុនា ឆ្នាំ២០១៧

ស្នាមមេដៃ

(ដើមបណ្ដឹង)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ១៣១២ អ.ក

ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៨

លេខ: ១១៥ ដកសព/១៩

# ដីកាសន្និដ្ឋានស្ថាពរ

យើង ............................ តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៩៩៩ ដកសស/១៨ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៨

-បានឃើញសំណុំរឿងស៊ើបសួរលេខ ៦៧៣ សស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៨

-បានឃើញដីកាបញ្ជូនឱ្យឆ្លើយដើម្បីបញ្ចប់ការស៊ើបសួរលេខ ៤០ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៩

-បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យលេខ ០៦៧ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរ

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**យល់ឃើញថា៖**

នាមត្រកូល ៖ . .............. នាមខ្លួន៖ ................... នាមហៅក្រៅ៖ គ្មាន ភេទ៖ ស្រី

អាយុ ៖ ៥៥ឆ្នាំ

ទីកន្លែងកំណើត ៖ ភូមិយស្សបាត ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល

ទីលំនៅបច្ចុប្បន្ន ៖ ភូមិឈើទាល២ ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល

មុខរបរ ៖ អ្នករើសអេតចាយ

ស្ថានភាពគ្រួសារ ៖ រៀបការ (ប្តីឈ្មោះ..................."រស់" មានកូន៖ ០៣ នាក់)

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ....................."ស្លាប់" ម្តាយឈ្មោះ៖ ..................."ស្លាប់"

ជានីតិជន។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖**ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

**ឃើញថា**[19]**៖** កាលពីថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ វេលាម៉ោង ១៧ និង ៤០ នាទី មានជនរងគ្រោះឈ្មោះ ............................ និងឈ្មោះ ......................... កំពុងផឹកស្រាថ្នាំនៅចំណុចក្បែរទំនប់សម្តេចជា ស៊ីម ស្ថិតនៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ក៏មានជនសង្ស័យឈ្មោះ ............................ បានជិះកង់មកហៅប្តីឈ្មោះ **វ៉ាន់ វិត** ពេលនោះឈ្មោះ ............................បានស្រែកជេរប្រមាថមក លើជនសង្ស័យឈ្មោះ ............................ រំពេចនោះស្រាប់តែជនសង្ស័យឈ្មោះ ..........................បានទាញយកដំបងឈើវាយទៅលើជនរងគ្រោះឈ្មោះ ......................... ត្រូវចំក្បាលបណ្តាលឲ្យរងរបួស។

---

19 រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់ (ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ)

**ឃើញថា៖**

<u>**នៅដំណាក់កាលស៊ើបអង្កេតរបស់អធិការដ្ឋានស្រុកកៀនស្វាយ**</u>

យោងតាមពាក្យបណ្តឹងរបស់ឈ្មោះ .............................. អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ បានផ្តើមធ្វើការស៊ើបអង្កេតដោយបានចុះទៅពិនិត្យ និងវិភាគកន្លែងកើតហេតុ ក៏ដូចជាធ្វើកំណត់ហេតុសួរ និងស្តាប់យកចំលើយនូវឈ្មោះ៖

-ជនត្រូវចោទឈ្មោះ ................................. បានឆ្លើយបំភ្លឺថា៖ កាលពីថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ វេលាម៉ោង ១៦ នាទីរសៀល រូបខ្លួនបានអង្គុយផឹកស្រាថ្នាំជាមួយនឹងឈ្មោះ ម៉ាម់ ដោយផឹកស្រាថ្នាំ រហូតដល់ម៉ោង ១៧ និង ០៥ នាទី ទើបឈប់ រួចរូបខ្លួនក៏បានជិះកង់ទៅហៅប្តីរបស់ខ្លួនឈ្មោះ.............................. ដែលកំពុងផឹកស្រាជាមួយនឹងជនរងគ្រោះឈ្មោះ ......................... ដែលខណៈពេលនោះ ស្រាប់តែ ឈ្មោះ ........................ បានស្រែកជេរប្រមាថនូវពាក្យអសុរោះជាច្រើនមកលើរូបខ្លួន ធ្វើឲ្យរូបខ្លួនខឹង ក៏បានទាញយកដំបងឈើប្រវែងប្រហែល ៧០ សង់ទីម៉ែត្រ ស្ទុះទៅវាយលើឈ្មោះ ................................. ត្រូវ ចំក្បាលបណ្តាលឲ្យបែកចេញឈាមរងរបួសប្រាកដមែន។

-សាក្សីបំភ្លឺឈ្មោះ .......................... បានឆ្លើយបំភ្លឺថា៖ កាលពីថ្ងៃកើតហេតុវេលាម៉ោង ១៧ និង ៤០ នាទី ខណៈពេលរូបខ្លួនកំពុងផឹកស្រាថ្នាជាមួយនឹងឈ្មោះ ...................... នៅលើទំនប់សម្តេច **ជា ស៊ីម** ស្ថិតនៅក្នុងភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល រួចក៏មានប្រពន្ធរបស់ខ្លួន ឈ្មោះ ......................... បានជិះកង់មកដល់ ឃើញដូច្នេះ ឈ្មោះ ....................... ក៏បានស្រែកជេរប្រមាថមក លើប្រពន្ធរបស់ខ្លួនឈ្មោះ ........................ រំពេចនោះស្រាប់តែប្រពន្ធរបស់ខ្លួនឈ្មោះ .................. បានស្ទុះទៅទាញយកដំបងឈើវាយទៅលើឈ្មោះ ........................ ត្រូវចំក្បាលបណ្តាលឲ្យបែកចេញ ឈាមប្រាកដមែន។

-តាមកំណត់ហេតុចាប់យកវត្ថុតាងចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់អធិការដ្ឋាន នគរបាលស្រុកកៀនស្វាយរួមមាន៖ ដំបងឈើមូលប្រវែង ៦៥ សង់ទីម៉ែត្រ ។

-តាមកំណត់ហេតុទទួលស្គាល់វត្ថុតាងចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់អធិការដ្ឋាន នគរបាលស្រុកកៀនស្វាយ។

-សៀវភៅរូបថតចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ។

-តាមកំណត់ហេតុសរុបនៃការឃាត់ខ្លួនចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់អធិការដ្ឋាន នគរបាលស្រុកកៀនស្វាយ ជនសង្ស័យឈ្មោះ ........................... ត្រូវបានឃាត់ខ្លួននៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ វេលាម៉ោង ២៣ និង ២០ នាទី។

<u>**នៅដំណាក់កាលស៊ើបអង្កេតរបស់តំណាងអយ្យការ**</u>

ក្រោយពីបានពិនិត្យរបាយការណ៍សរុបលេខ ៣៧៦ របក ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ តំណាងអយ្យការបានធ្វើកំណត់ហេតុសួរយកចំលើយជនត្រូវចោទឈ្មោះ ................................ ដោយឈ្មោះនេះបានឆ្លើយសារភាពថា៖ កាលពីថ្ងៃកើតហេតុថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ វេលាម៉ោង ១៦ និង ០៥ នាទីរសៀល រូបខ្លួនបានអង្គុយផឹកស្រាថ្នាំជាមួយនឹងឈ្មោះ ....................... រហូតដល់ ១៧ និង ០៥ នាទីទើបឈប់ រួចខណៈពេលរូបខ្លួនទៅសួរនាំប្តីនៅកន្លែងផឹកស៊ីស្រាប់តែមានឈ្មោះ ...................... ស្ថិតនៅក្នុងស្ថានភាពស្រវឹងស្រា បានស្រែកជេរប្រមាថមកលើរូបខ្លួននូវពាក្យអសុរោះ ភ្លាមនោះរូបខ្លួនខឹង ក៏បានទាញដំបងស្នុះទៅវាយមកលើឈ្មោះ ...................... ត្រូវចំក្បាលបណ្តាលឲ្យរងរបួសចេញឈាមប្រាកដមែន។

បន្ទាប់មកតំណាងអយ្យការបានធ្វើការចោទប្រកាន់លើឈ្មោះ ........................ ភេទស្រី អាយុ ៥៥ ឆ្នាំ ពីបទ **ហិង្សាដោយចេតនា** តាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៩៩៩ ដកសស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

## <u>នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ</u>

តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរបានផ្តើមធ្វើការស៊ើបសួរដោយដាក់ជនត្រូវចោទឈ្មោះ ......................... ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ តាមបញ្ញត្តិនៃមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ និងបានធ្វើកំណត់ហេតុស្តាប់ និងសួរយកចម្លើយនូវឈ្មោះ៖

-ជនត្រូវចោទឈ្មោះ ............................ បានឆ្លើយបំភ្លឺថា៖ រូបខ្លួនសូមរក្សាចម្លើយដែលរូបខ្លួនបាន ឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការ ទុកជាបានការទាំងស្រុង ដោយសូមបញ្ជាក់បន្ថែមថា៖ នៅថ្ងៃកើតហេតុរូបខ្លួនពិតជាបានធ្វើសកម្មភាពយកដំបងឈើវាយទៅលើជនរងគ្រោះឈ្មោះ ............... បណ្តាលឲ្យបែកក្បាលហូរឈាម រងរបួសប្រាកដមែន។

-តាមដីកាសម្រេចឃុំខ្លួនបណ្តោះខ្លួនបណ្តោះអាសន្នលេខ ២៨២៩ ដក.សយខ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ជនត្រូវចោទឈ្មោះ ............................ ត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៨។

### ឃើញថា៖

-តាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ ........................ តាមចម្លើយរបស់សាក្សីបំភ្លឺឈ្មោះ .............................. តាមកំណត់ហេតុចាប់យកវត្ថុតាង តាមកំណត់ហេតុទទួលស្គាល់វត្ថុតាងចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ព្រមទាំងតាមសៀវភៅរូបថតចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ អាចបញ្ជាក់បានថាពិតជាកើតមានអង្គហេតុនៃ **ហិង្សាដោយចេតនា** ប្រព្រឹត្តឡើងនៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ប្រាកដមែន។

-ជនត្រូវចោទឈ្មោះ ......................... បានឆ្លើយសារភាពតាំងពីដំណាក់កាលមន្ត្រីនគរបាលយុត្តិ ធម៌ រហូតដល់ដំណាក់កាលចៅក្រមស៊ើបសួរដូចគ្នាថាៈកាលពីថ្ងៃកើតហេតុរូបខ្លួនពិតជាបានប្រើ ហិង្សាវាយទៅលើជនរងគ្រោះឈ្មោះ ..........................ដោយប្រើដំបងឈើបណ្តាលឲ្យរងរបួសប្រាកដមែន។

-ជនត្រូវចោទឈ្មោះ ........................ពិតជាបានប្រើហិង្សាវាយមកលើជនរងគ្រោះឈ្មោះ ..........................បណ្តាលឲ្យរបួស ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទ **ហិង្សាដោយចេតនា។**

-អំពើរបស់ជនត្រូវចោទឈ្មោះ ..........................បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ជាបទ **ហិង្សាដោយចេតនា** ដែលជាអំពើបំពានលើច្បាប់ដូចមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

- ជនត្រូវចោទឈ្មោះ .............................. ជានីតិជន មានស្មារតីដឹងខុសត្រូវគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ ។

-មានភស្តុតាងដាក់បន្ទុកលើឈ្មោះ .......................... **ពីបទ ហិង្សាដោយចេតនា** ប្រព្រឹត្តិនៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១៨ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

**<u>ហេតុដូច្នេះសម្រេច</u>**

ប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ .......................... ភេទស្រី អាយុ ៥៥ឆ្នាំ (ក្នុងឃុំ) ទៅជំនុំជម្រះ ។

ថ្ងៃ សុក្រ ០៤កើត ខែ មាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

កណ្តាល, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៩

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្ដាល

លេខ: ដកមចក/១៩

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ........................ តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៣ អ.ក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល និង សំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងវត្ថុតាងនានា ។

-បានឃើញរបាយការណ៍លេខ ០៥៧ រ.ប.ក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៩ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា ៖

១. អវត្តមានបទល្មើស

☐ ១.១. អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

☐ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

☐ ៣.១. ការដកពាក្យបណ្ដឹង

☐ ៣.២. ការលើកលែងទោសជាទូទៅ

☐ ៣.៣. មរណភាពជនល្មើស

☐ ៣.៤. ផុតអាជ្ញាយុកាល

☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦. អាជ្ញាអស់ជំនុំ

☐ ៣.៧. ការសម្របសម្រួលជាមួយរដ្ឋ

☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល

☐ ៣.៩. អភ័យឯកសិទ្ធិ

☐ ៣.១០. អនិយ័តភាពនៃនីតិវិធី

☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[20]

៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

☐ ៤.១. ការស្វែងរកមិនបានផល

☐ ៤.២. ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[21]

☐ ៤.៣. ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤.៤. ការខកខានរបស់ដើមបណ្តឹង

☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

☐ ៤.៧. និយ័តកម្មដោយឯកឯង[22]

☐ ៤.៨. ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២. សន្ធានកម្ម[23]

☐ ៥.៣. អធិបញ្ញាផ្តល់ការព្យាបាល

---

[20] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[21] ដើមបណ្តឹងឈប់ប្តឹង

[22] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[23] ករណីថែងដោយច្បាប់

☐ ៥.៤. ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥. និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[24]

☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬនៃវិជ្ជាជីវៈ

☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[25]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងទៀត

☐ ៦.១. ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

☐ ៨.១. ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការសង្កេតផ្សេងៗ៖** កាលពីថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៩ វេលាម៉ោង ១៩ និង១៥ នាទី មានម៉ូតូមួយគ្រឿងម៉ាក ហុងដា ឌ្រីម C១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1BH-XXXX (មានទិសដៅពីជើងមកត្បូង) បើកបរដោយឈ្មោះ ………….. ភេទប្រុស អាយុ១៧ឆ្នាំ ដោយមានឈ្មោះ ………………. ភេទប្រុស អាយុ២០ឆ្នាំ និងឈ្មោះ ……………………. ភេទប្រុស អាយុ២០ឆ្នាំ រួមដំណើរជាមួយ ហើយនៅពេលបើកបរមកដល់ចំណុចផ្លូវលេខ ២៦១ ស្ថិតនៅក្នុងភូមិគ្រោលគោ ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ក៏បុកនឹងម៉ូតូមួយគ្រឿងម៉ាក ហុងដា ឌ្រីម C១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1DF-XXXX (មកពីទិសផ្ទុយគ្នា) បើកបរដោយឈ្មោះ ………………….. ភេទប្រុស អាយុ២៣ឆ្នាំ និងអ្នករួមដំណើរចំនួន១នាក់ឈ្មោះ ……………………. ភេទប្រុស អាយុ៤២ឆ្នាំ ដែលមកពីទិសផ្ទុយគ្នា។

---

[24] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមាន ឱ្យឈប់ប្រព្រឹត្ត

[25] ករណីចែងដោយច្បាប់

## <u>បានឃើញ</u>

-កំណត់ហេតុស្ដាប់ចម្លើយចុះថ្ងៃទី ០៧ ខែ មេសាឆ្នាំ ២០១៩ របស់ឈ្មោះ វង់ សុខលី

-កំណត់ហេតុត្រួតពិនិត្យកន្លែងកើតហេតុចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៩ របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល ។

-កំណត់ហេតុត្រួតពិនិត្យជនរងគ្រោះថ្នាក់ចរាចរណ៍ចុះថ្ងៃទី ០៧ ខែ មេសាឆ្នាំ ២០១៩របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល។

-កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ ២០១៩ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

-កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ២០១៩ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

-របាយការណ៍លេខ ០៤៧ របក ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៩ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

-របាយការណ៍បូកសរុប ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៩ របស់ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

- កំណត់ហេតុសួរចម្លើយចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៩ របស់ឈ្មោះ…………………ភេទ ប្រុស អាយុ ២១ឆ្នាំ។

-សេចក្ដីចំលងសំបុត្រទទួលមរណភាព ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ ……………។

-សេចក្ដីចំលងសំបុត្រទទួលមរណភាព ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ ………………។

**<u>យល់ឃើញថា៖</u>**

- ដោយសារមូលហេតុនៃមរណភាពជនល្មើស នាំឱ្យមានការរលត់នូវបណ្តឹងអាជ្ញា[26] ដូចនេះគប្បីតម្កល់រឿងទុកឥតចាត់ការ។

**<u>ហេតុដូច្នេះសម្រេច</u>**

-តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ៥៥៣ អ.ក ចុះថ្ងៃទី **០៩** ខែ **ឧសភា** ឆ្នាំ **២០១៩** ទុកឥតចាត់ការតទៅ ៕

ថ្ងៃ អង្គារ ០៨រោច ខែ កត្តិក ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

កណ្តាល, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩

**តំណាងអយ្យការ**

[26] មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា